# ព្រឹត្តិបត្រព័ត៌មានសមាគមឧកញ៉ាកម្ពុជា

## ឆ្នាំទី១ លេខ៣ ត្រីមាសទី៣ ឆ្នាំ២០២៤




រៀបរៀងដោយៈ
អគ្គលេខាធិការដ្ឋាន នៃសមាគមឧកញ៉ាកម្ពុជា

# មាតិកា


- អ្នកឧកញ៉ា ហ៊ុន ឡាក់ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន......១
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមពិធីពិសាភោជនាហារ នៃវេទិកាធុរកិច្ចបារាំង-កម្ពុជា.......២
- អ្នកឧកញ៉ាហ៊ុនឡាក់ចូលរួមកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពនិងកំណត់ទិសដៅការងាររបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ក.ផ.ផ.) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចធិបតីនាយករដ្ឋមន្ត្រី..........................................................៤
- សមាគមឧកញ៉ាកម្ពុជាដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយតំណាងសហគមន៍កសិកម្មក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង.................៥
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ព្រមទាំងថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីចុះអនុស្សរណៈនៃការយោគ យល់គ្នារវាងសមាគមឧកញ៉ាកម្ពុជា និង មន្ទីរពេទ្យអន្តរជាតិ អរៀនដា.........................................................................................៦
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីបញ្ចុះបឋមសិលាសាងសង់សារមន្ទីរសម្តេចព្រះព្រហ្មរតនមុនី ពិន សែម...........................................................................................................................៨
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោក អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ចូលរួមកិច្ចប្រជុំពេញអង្គលើកទី១នៃក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ក.ផ.ផ.)..............................................៩
- ពិធីចុះហត្ថលេខាលើចុះអនុស្សរណៈយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជានិង សារព័ត៌មានស៊ីស៊ីថាមស៍ ( TheCambodiaChina Times )......................................................................................................................................១០
- លោកអ្នកឧកញ៉ាលីយ៉ុងផាត់ប្រធានសមាគមឧកញ៉ាកម្ពុជាដឹកនាំកិច្ចប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាលលើកទី៨ដើម្បីពិនិត្យរបាយការណ៍និងវឌ្ឍនភាពការងារប្រចាំឆមាសទី១ ឆ្នាំ២០២៤......................................................................................១១
- ពិធីសំណេះសំណាល និងពិសាភោជនាហារសាមគ្គី នៃមហាគ្រួសារសមាគមឧកញ៉ាកម្ពុជានិង សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត..............................................................................................................១៣
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត១៧
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាង សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ជាមួយលោកស្រី Mio Kawada អនុប្រធានអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន..........................................................................................................................១៨
- សន្និសីទស្តីពីការបង្កើតកិច្ចសហការរួមគ្នាកម្ពុជា-ជប៉ុន ចាប់យកឱកាសធុរកិច្ចនៃឥណទានកាបូននៅកម្ពុជាដោយប្រើប្រាស់បច្ចេកវិទ្យាបៃតង និងលំហអាកាសទំនើបចុងក្រោយបំផុតរបស់ប្រទេសជប៉ុន ព្រមទាំងកម្មវិធី«ជំនួបផ្គូផ្គងធុរកិច្ចកម្ពុជា-ជប៉ុន» ក្រោមប្រធានបទ៖ "ធុរកិច្ចឥណទានកាបូន និងបរិយាកាសវិនិយោគនៅកម្ពុជា" ២០
- សមាគមឧកញ៉ាកម្ពុជានិងJETROប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីបង្កើតនូវកាលានុវត្តភាពធុរកិច្ចរវាងធុរជនជប៉ុននិងសមាជិកនៃសមាគមឧកញ៉ាកម្ពុជា...................................................................................................................២២
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជា និងក្រុមហ៊ុន SAGRI Corporation Private Limited ក្រោមអធិបតីភាពឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម............................២៤

- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជា និងក្រុមហ៊ុន SAGRI Corporation Private Limited ក្រោមអធិបតីភាពឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម....................................២៦
- ឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន ថ្លែងលើកទឹកចិត្តទៅកាន់បណ្ដាអ្នកវិនិយោគិនជប៉ុន សូមបន្តចូលរួមសហការជាមួយសមាគមឧកញ៉ាកម្ពុជាដើម្បីជំរុញការផ្លាស់ប្ដូរព័ត៌មានរបស់ភាគីទាំងពីរឱ្យបានកាន់តែល្អប្រសើរ....................................២៦
- ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ផ្ដល់កិត្តិយសអញ្ជើញថ្លែងសុន្ទរកថាគន្លឹះអំពីបរិយាកាសវិនិយោគនៅកម្ពុជាក្នុងជំនួបធុរកិច្ចកម្ពុជា-ជប៉ុន....................................២៨
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ទទួលជួបសម្ដែងការគួរសមជាមួយគណៈប្រតិភូតំណាងអង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុន ( Japan External Trade Organization – JETRO ) ប្រចាំនៅកម្ពុជា....................................៣០
- អ្នកឧកញ៉ា សៀ ឫទ្ធី ទទួលជួបការសម្ដែងការគួរសម និង ពិភាក្សាការងារជាមួយ ឯកឧត្តម ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថានប្រចាំព្រះរាជាណាចក្រកម្ពុជា....................................៣២
- អ្នកឧកញ៉ា ហ៊ុន ឡាក់រួមជាមួយអ្នកឧកញ៉ា លី សាំងឡេង និងឧកញ៉ា អាន ឌីណា ទទួលជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រុមហ៊ុន PCA Global Associates ដែលវិនិយោគលើវិស័យបច្ចេកវិទ្យា....................................៣៤
- ប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងដំណើរទស្សនកិច្ចទីក្រុងសៀមិន សាធារណរដ្ឋប្រជាមានិតចិន....................................៣៥
- ឯកឧត្តមឧបនាយករដ្ឋមន្ត្រីស៊ុនចាន់ថុលដឹកនាំគណៈប្រតិភូកម្ពុជាអញ្ជើញទទួលទានអាហារនិងពិភាក្សាការងារជាមួយលោកបណ្ឌិត Mohammed Al Zarooni ប្រធានអង្គការតំបន់សេរីពិភពលោក ( World Free Zone Organization ) និងជានាយកប្រតិបត្តិនៃតំបន់សេដ្ឋកិច្ចរួមបញ្ចូលឌូបៃ ( Dubai Integrated Economic Zones ) ....................................៣៧
- អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងវេទិកាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មនៃ RCEP ដែលជាផ្នែកមួយនៃបេសកកម្មក្នុងទីក្រុងសៀមិន....................................៣៩
- គណៈប្រតិភូកម្ពុជាចុះទស្សនកិច្ចមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិក្រុងសៀមិន ( Xiamen International Con– vention and Exhibition Center ) ....................................៤០
- ថ្នាក់ដឹកនាំក៏ដូចជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបបានអញ្ជើញចូលរួមក្នុងកម្មវិធីពិសេស Gala Dinner នៃព្រឹត្តិការណ៍ Gumball 3000 x Chip Mong in Cambodia នៅមុខប្រាសាទបាយ័ន ខេត្តសៀមរាប....................................៤២
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវ ព្រមទាំងថ្នាក់ដឹកនាំ និងសមាជិកនៃសមាគម ឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមពិធីបើកពិព័រណ៍អាពាហ៍ពិពាហ៍ប្រចាំឆ្នាំ២០២៤ ....................................៤៣
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំសមាជិកចូលរួមពិធីកាន់បិណ្ឌទី៤ នៅវត្តកែវមុនីរស្មី ហៅវត្ត កន្ទួត ស្ថិតនៅភូមិកន្ទួត ឃុំសង្កែសាទប ស្រុកឧិរ៉ាល់ ខេត្តកំពង់ស្ពឺ....................................៤៤
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ចាត់តាំង អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចូលរួមបេសកកម្មទាក់ទាញ និងជំរុញវិនិយោគនៅសហរដ្ឋអាម៉េរិក និងកាណាដា....................................៤៦
- អ្នកឧកញ៉ា ហ៊ុន ឡាក់ ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងសហព័ន្ធស្រូវអង្ករកម្ពុជាជាមួយនឹងក្រុមហ៊ុOtis McAllister Inc ....................................៤៧
- ប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងជំនួបពិភាក្សាលើប្រធានបទ «បច្ចុប្បន្នភាពនៃបរិយាកាសវិនិយោគនៅកម្ពុជា»....................................៤៩

- ប្រតិភូសមាគមឧកញ៉ាកម្ពុជា បន្តចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ក្នុងឱកាសជួបពិភាក្សាការងារ និងទទួលទាន អាហារថ្ងៃត្រង់ធុរកិច្ច ជាមួយគណៈប្រតិភូក្រុមប្រឹក្សាតំបន់ឈូងសមុទ្រ ( Bay Area Council - BAC ) ............................................៥១
- ជំនួបពិភាក្សាការងាររវាង ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រុមហ៊ុន Levi Strauss & Co ..................៥២
- អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ក្នុងជំនួបសំណេះសំណាល និងពិភាក្សាការងារជាមួយ លោកជំទាវ Karen Bass អភិបាលក្រុងឡូសអែនជែលលេស នៃរដ្ឋកាលីហ្វ័រញ៉ា..........................................៥៣
- សិក្ខាសាលាស្តីពី“បរិយាកាសវិនិយោគនៅកម្ពុជា”បង្ហាញជូនអំពីពីវឌ្ឍនភាពថ្មីៗដល់វិស័យឯកជនដែលមានមូលដ្ឋានក្នុងក្រុងឡុងប៊ិច និងក្រុងឡូសអែនជែលលេស.........................................................................................................................៥៤
- ឯកឧត្តម ស៊ុន ចាន់ថុល ដឹកនាំប្រតិភូកម្ពុជាអញ្ជើញទស្សនកិច្ចទីស្នាក់ការកណ្តាលក្រុមហ៊ុន SpaceX របស់លោក Elon Musk.....៥៥
- កិច្ចពិភាក្សាជាមួយថ្នាក់ដឹកនាំរតនាគារនៃរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាម៉េរិកក្នុងគោលបំណងផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយអំពីបរិយាកាសវិនិយោគនៅកម្ពុជា...........................................................................................................................៥៦
- ប្រតិភូសមាគមឧកញ៉ាកម្ពុជាមានក្តីសោមនស្សរីករាយដែលបានជួបសំណេះសំណាលសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋខ្មែរ-អាម៉េរិកាំងដែលកំពុងរស់នៅក្រុងឡុងប៊ិច នៃរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាម៉េរិក.........................................................................................៥៧
- ជំនួបភាក្សាការងារជាមួយលោក Daniel Chapman ស្ថាបនិក និងជានាយកប្រតិបត្តិក្រុមហ៊ុន Argentem Creek ដើម្បីជម្រាបអំពីព័ត៌មានសក្តានុពលសម្រាប់ការវិនិយោគឯកជននៅប្រទេសកម្ពុជា...................................................................................៥៨
- ប្រតិភូសមាគមឧកញ៉ាកម្ពុជាចាប់ផ្តើមបេសកកម្មនៅប្រទេសកាណាដាតាមរយៈជំនួបពិភាក្សាតុមូលស្តីពីបរិយាកាសវិនិយោគនៅកម្ពុជាជូនបណ្ឌាធុរជនក្នុងទីក្រុងម៉ុងត្រេអាល់..............................................................................................................៥៩
- សមាគមឧកញ៉ាកម្ពុជា ចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយស្ថាប័ន Excellence Industrielle Saint-Laurent ( FISL ) របស់ខេត្តកេបិចក្នុងគោលដៅពង្រឹងការវិនិយោគទ្វេភាគី និងសម្របសម្រួលការផ្លាស់ប្តូរសេដ្ឋកិច្ច.................................................៦០
- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ដឹកនាំគណៈប្រតិភូកម្ពុជាចូលជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាអាត្លង់ទិក ( The Atlantic Council of United States )........................................................................................................................៦១
- អ្នកឧកញ៉ា ហ៊ុន ឡាក់ ចូលរួមអមដំណើរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុលក្នុងជំនួបចង្អៀតជាមួយឯកឧត្តម Ted Osius និងជំនួបពិសាអាហារធុរកិច្ចជាមួយសមាជិក សមាជិកានៃក្រុមប្រឹក្សាធុរកិច្ចអាម៉េរិក-អាស៊ាន ( US-ABC )....................................៦៣
- លោកអ្នកឧកញ៉ា ហុង ស៊ួន ស៊ីគង់ទ្រីវ ដឹកនាំសមាជិកសមាគមឧកញ៉ាកម្ពុជា ប្រគេនទេយ្យទាន និងបច្ច័យសម្រាប់ព្រះសង្ឃគង់នៅវត្តមហាមន្ត្រី ក្នុងរាជធានីភ្នំពេញ.................................................................................................................៦៤

# អ្នកឧកញ៉ា ហ៊ិន ឡាក់ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន




ព្រឹកថ្ងៃព្រហស្បតិ៍ ១៣រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ិន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជារួមជាមួយលោកស្រី Marisa Haruta ប្រធានតំណាងអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុនប្រចាំកម្ពុជាបានចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយឯកឧត្តម អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាននៅទីស្តីការក្រសួងបរិស្ថាន។

គោលបំណងនៃជំនួបសម្តែងការគួរសមនេះគឺដើម្បីជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីអំពីកិច្ចសហការរវាងសមាគមឧកញ៉ាកម្ពុជា (COA) អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) ប្រចាំកម្ពុជា និងភ្នាក់ងាររុករកលំហអាកាសជប៉ុន(JAXA)ក្នុងការរៀបចំ"សន្និសីទកម្ពុជា-ជប៉ុនស្តីពីការលើកកម្ពស់ការយល់ដឹងអំពីធុរកិច្ចឥណទានកាបូនដោយប្រើប្រាស់បច្ចេកវិទ្យាបៃតងនិងផ្កាយរណប"ព្រមទាំងស្នើសូមការគាំទ្រក៏ដូចជាគោរពអញ្ជើញឯកឧត្តមរដ្ឋមន្ត្រីចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាស្វាគមន៍ក្នុងកម្មវិធីខាងលើផងដែរ។

សូមជម្រាបជូនថា សន្និសីទនេះគឺជាព្រឹត្តិការណ៍លើកដំបូងនៅកម្ពុជាដែលនឹងមានការចូលរួមពីវាគ្មិនកម្ពុជា-ជប៉ុនជាអ្នកជំនាញផ្នែកធុរកិច្ច បរិស្ថាន កសិកម្ម ឧស្សាហកម្ម និងបច្ចេកវិទ្យា មកធ្វើការចែករំលែកចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងធុរកិច្ចឥណទានកាបូនដោយប្រើប្រាស់បច្ចេកវិទ្យាបៃតង និងផ្កាយរណបដើម្បីជាមូលដ្ឋានសម្រាប់ធុរជនកម្ពុជាចាប់យកឱកាសក្នុងប្រតិបត្តិការអាជីវកម្មថ្មីតាមរយៈការបង្កើតនិងលក់ឥណទានកាបូនក្នុងវិស័យធុរកិច្ចបៃតង។

សន្និសីទដ៏មានសារៈសំខាន់នេះនឹងប្រារព្ធធ្វើឡើងនាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤ នាពេលខាងមុខនេះដោយមានការចូលរួមពីថ្នាក់ដឹកនាំរដ្ឋាភិបាល និងវិស័យឯកជនកម្ពុជា-ជប៉ុន និងភាគីពាក់ព័ន្ធចំនួនសរុបប្រមាណ ៣០០នាក់ដោយនាពេលរសៀលក៏នឹងមានការរៀបចំជំនួបពាណិជ្ជកម្មនិងពិសាភោជនាហារធុរកិច្ចរវាងគណៈប្រតិភូធុរកិច្ចជប៉ុន និងសមាជិកសមាគមឧកញ៉ាកម្ពុជាដើម្បីជាវេទិកាស្វែងយល់អំពីបរិយាកាសធុរកិច្ច និងសក្តានុពលវិនិយោគនៅកម្ពុជាព្រមទាំងជាឱកាសសម្រាប់ធុរជនកម្ពុជា–ជប៉ុនផ្គូផ្គងដៃគូធុរកិច្ចទៅវិញទៅមកសម្រាប់កិច្ចសហប្រតិបត្តិការនាពេលអនាគតផងដែរ។

# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីពិសាភោជនាហារ នៃវេទិកាធុរកិច្ចបារាំង-កម្ពុជា













នាល្ងាចថ្ងៃអង្គារ ៤កើត ខែអាសាឍ ឆ្នាំរោង ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងពិធីពិសាភោជនាហារនៃវេទិកាធុរកិច្ចបារាំងកម្ពុជាដែលត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្ថានទូតបារាំង សភាពាណិជ្ជកម្ម និងឧស្សាហកម្មបារាំងនៅកម្ពុជា ព្រមទាំងសមាគមឧកញ៉ាកម្ពុជានិងដៃគូសហការដទៃ ទៀត។ កម្មវិធីនេះមានការចូលរួមពីឯកឧត្តមឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ព្រមទាំងឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា និងធុរជន កម្ពុជាបារាំងជាច្រើនរូបក្នុងគោលបំណងផ្តល់ឱកាសដល់អ្នកចូលរួមទាំងអស់អាចកសាងនិងផ្លាស់ប្តូរទំនាក់ទំនងធុរកិច្ចទៅវិញទៅមកក្នុងបរិយាកាសដ៏ស្និទ្ធស្នាលសម្រាប់កិច្ចសហប្រតិបត្តិការនាពេលបច្ចុប្បន្ន និងអនាគត។

លោកអ្នកឧកញ៉ាប្រធានក៏បានបញ្ជាក់នូវសុទិដ្ឋិនិយមខ្ពស់ថាវេទិកាដ៏មានសារៈសំខាន់នេះនឹងត្រូវបានរៀបចំយ៉ាងទៀងទាត់ជាបន្តបន្ទាប់ដើម្បីជាសារៈប្រយោជន៍ដល់សហគមន៍ធុរកិច្ចបារាំង-កម្ពុជាពិសេសជំរុញដល់សកម្មភាពពាណិជ្ជកម្មឱ្យកាន់តែសកម្មនិងលើកកម្ពស់កំណើនសេដ្ឋកិច្ចនៃប្រទេសទាំងពីរ។ជាងនេះទៅទៀតលោកអ្នកឧកញ៉ាបានមានប្រសាសន៍ថា សមាគមឧកញ៉ាកម្ពុជាបានត្រៀមខ្លួនរួចជាស្រេចក្នុងការស្វាគមន៍ស្ថាប័នធុរកិច្ចជាតិនិងអន្តរជាតិដែលមានចំណាប់អារម្មណ៍ក្នុងកិច្ចសហការលើគំនិតផ្តួចផ្តើមណាមួយក្នុងការលើកកម្ពស់ទំនាក់ទំនងធុរកិច្ចនិងជំរុញសកម្មភាពពាណិជ្ជកម្មជាក់ស្តែងពិធីពិសាភោនាហារធុរកិច្ចនាថ្ងៃនេះជាដើម។

ទន្ទឹមនឹងនេះ ឯកឧត្តម Jacque Pellet ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជាបានលើកឡើងថា បើទោះបីជាស្ថានភាពវិនិយោគផ្ទាល់ពីបារាំងមកកម្ពុជាមានកម្រិតនៅឡើយប៉ុន្តែក្នុងនាមឯកឧត្តមផ្ទាល់នឹងព្យាយាមបន្ថែមទៀតជំរុញពង្រីកការវិនិយោគដោយផ្ទាល់ពីបារាំងនៅកម្ពុជាឱ្យបានច្រើន។

ជាមួយគ្នានេះដែរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបង្ហាញជំនឿចិត្តយ៉ាងមុតមាំថាបន្ទាប់ពីវេទិកាធុរកិច្ចនេះរួចរាល់កំណើនវិនិយោគិនបារាំងនៅកម្ពុជានឹងមានការកើនឡើងមួយកម្រិតទៀត។ជាងនេះទៅទៀតនៅមុនបំណាច់ឆ្នាំ២០២៤នេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីនឹងអញ្ជើញធ្វើដំណើរទៅប្រទេសបារាំងដើម្បីគោះទ្វារទាក់ទាញវិនិយោគិនឱ្យមកវិនិយោគនៅកម្ពុជាបន្ថែមទៀតផងដែរ។














## អ្នកឧកញ៉ា ហ៊ុន ឡាក់ ចូលរួមកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព និងកំណត់ទិសដៅការងាររបស់ក្រុមប្រឹក្សាភិបាល សិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ក.ផ.ផ.) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចធិបតីនាយករដ្ឋមន្ត្រី



នាថ្ងៃពុធ ៥ កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនេះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគម និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានចូលរួមកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពនិងកំណត់ទិសដៅការងាររបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ក.ផ.ផ.) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សូមបញ្ជាក់ថា(ក.ផ.ផ.)គឺជាយន្តការស្ថាប័នដែលមានលក្ខណៈអំណោយផលនិងបើកទូលាយដោយអនុញ្ញាតឱ្យវិស័យឯកជនចូលរួមពេញលេញជាមួយរាជរដ្ឋាភិបាលតាមរយៈក្រសួងស្ថាប័នពាក់ព័ន្ធព្រមទាំងថ្នាក់ដឹកនាំនិងតំណាងនៃវិស័យឯកជន ដូចជា សមាគមឧកញ៉ាកម្ពុជា សភាពាណិជ្ជកម្មកម្ពុជារួមជាមួយបណ្តាសមាគមនិងក្រុមហ៊ុនដែលកំពុងបំពេញការងារលើវិស័យទេសចរណ៍ជាដើម ដោយឈរលើគោលការណ៍ "រួមគិត រួមធ្វើ រួមទទួលខុសត្រូវ" ក្នុងការជំរុញការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាស្របតាមនិន្នាការទេសចរណ៍សាកលលោកនិងតំបន់ដែលកំពុងមានការវិវត្តយ៉ាងលឿនដែលទាមទារឱ្យមានភាពបត់បែនខ្ពស់ធានាឱ្យបាននូវការប្រកួតប្រជែង និរន្តរភាព បរិយាបន្ន និងភាពធន់នៃវិស័យទេសចរណ៍កម្ពុជា។











## សមាគមខ្ទុកញ៉ាកម្ពុជាដឹកនាំកិច្ចប្រជុំពិភាក្សាការងារ ជាមួយតំណាងសហគមន៍កសិកម្មក្នុងស្រុកព្រះស្ដេច ខេត្តព្រៃវែង

នាព្រឹកថ្ងៃពុធ ទី៥កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ សមាគមខុកញ៉ាកម្ពុជា បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយតំណាងសហគមន៍កសិកម្មក្នុងស្រុកព្រះស្ដេចខេត្តព្រៃវែង ដឹកនាំដោយ លោក ភុន សម្ផស្ស អភិបាលស្រុកព្រះស្ដេច ដោយមានការចូលរួមពីអ្នកជំនាញកសិកម្មជាច្រើនរូបផងដែរ។







កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងជម្រាបជូនតំណាងសហគមន៍កសិកម្មអំពីការចុះទស្សនកិច្ចសិក្សារបស់គណៈប្រតិភូធុរកិច្ចជប៉ុននៅតំបន់កសិកម្មស្រុកព្រះស្ដេចនាពេលខាងមុខដើម្បីសិក្សាស្វែងយល់អំពីទីតាំងភូមិសាស្រ្ត ប្រព័ន្ធធារាសាស្រ្ត និងការធ្វើកសិកម្មដំណាំស្រូវនៅក្នុងតំបន់នោះក៏ដូចជាលើកទឹកចិត្តប្រជាកសិករឱ្យចូលរួមអនុវត្តកសិកម្មបៃតងដែលជួយទ្រទ្រង់ដល់កៀ្សត្របរិស្ថានប្រព័ន្ធអេកូឡូស៊ីនិងកាត់បន្ថយការបំភាយឧស្ម័នកាបូនទៅក្នុងបរិយាកាសតាមរយៈការអនុវត្តគោលការណ៍ទាំង៦ ដូចជា ១.ការកៀរពង្រាបដីស្រែ, ២.ការប្រើប្រាស់ជី, ៣.ការគ្រប់គ្រងទឹក), ៤.ការដាំដុះដំណាំគម្របដី, ៥.ការប្រើប្រាស់ពូជស្រូវ, និង ៦.ការគ្រប់គ្រងសត្វល្អិត (IPM: Integrated Pest Management)។ ទន្ទឹមនឹងការអនុវត្តកសិកម្មបៃតងនេះ ប្រជាកសិករមិនត្រឹមតែអាចជួយធ្វើឱ្យគុណភាពដីមានជីវជាតិនិងប្រព័ន្ធអេកូឡូស៊ីមានដង្ហើមឡើងវិញដែលជួយបង្កើនទិន្នផលស្រូវអង្ករបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែជាឱកាសសម្រាប់ប្រជាកសិករស្វែងយល់អំពីធុរកិច្ចឥណទានកាបូននិងទទួលបានអត្ថប្រយោជន៍រយៈពេលវែងពីឥណទានកាបូនផងដែរ។

ជាលទ្ធផលនៃកិច្ចប្រជុំតំណាងសហគមន៍នីមួយៗបានសម្ដែងការស្វាគមន៍ចំពោះការចុះទស្សនកិច្ចខាងលើ និងគាំទ្រក្នុងការអនុវត្តសាកល្បងនូវគម្រោងកសិកម្មបៃតងដើម្បីជាប្រយោជន៍និងលើកកម្ពស់ជីវភាពប្រជាកសិករ ពិសេសប្រែក្លាយតំបន់កសិកម្មស្រុកព្រះស្ដេចក្លាយជាតំបន់កសិកម្មបៃតងគំរូដែលផលិត និងទាញផលប្រយោជន៍ពីឥណទានកាបូន។

## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ព្រមទាំងថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជា និង មន្ទីរពេទ្យអន្តរជាតិ អរៀនដា

រសៀលថ្ងៃសុក្រ ៧កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់រួមជាមួយថ្នាក់ដឹកនាំនិងសមាជិកនៃសមាគមឧកញ៉ាកម្ពុជាជាច្រើនទៀតបានអញ្ជើញចូលរួមជាអធិបតី និងជាភ្ញៀវកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង សមាគមឧកញ៉ាកម្ពុជា និងមន្ទីរពេទ្យអន្តរជាតិ អរៀនដា ក្នុងគោលបំណងផ្តល់ជូននូវអត្ថប្រយោជន៍ដ៏ពិសេសជូនដល់ថ្នាក់ដឹកនាំ សមាជិកក៏ដូចជាបុគ្គលិកនៃសមាគមឧកញ៉ាកម្ពុជា។



អ្នកឧកញ៉ា គួន ធីតា ស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យអន្តរជាតិ អរៀនដា បានថ្លែងថាមន្ទីរពេទ្យដ៏ទំនើប និងមានស្តង់ដារអន្តរជាតិមួយនេះមានចក្ខុវិស័យចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការលើកស្ទួយវិស័យសុខាភិបាលឱ្យកាន់តែល្អប្រសើរតាមរយៈការផ្តល់ជូននូវគុណភាពនិងស្តង់ដារអន្តរជាតិប៉ុន្តែមានតម្លៃសមរម្យដើម្បីឱ្យប្រជាពលរដ្ឋខ្មែរដែលមានជំងឺមិនចាំបាច់ស្វែងរកការព្យាបាលនៅក្រៅប្រទេសហើយមន្ទីរពេទ្យនេះបានយកចិត្តទុកដាក់ខ្លាំងទៅលើសេវាកម្មនិងគុណភាពនៃការព្យាបាលដោយបានប្រមូលផ្តុំនូវវេជ្ជបណ្ឌិតនិងបុគ្គលិកដែលមានសមត្ថភាពបទពិសោធន៍ក្រមសីលធម៌វិជ្ជាជីវៈនិងចាត់ទុកការជួយសង្គ្រោះអ្នកជំងឺជាអាទិភាពបំផុត។





ជាមួយគ្នានេះ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានមានប្រសាសន៍កោតសរសើរពីមន្ទីរពេទ្យអន្តរជាតិអរៀនដាទាំងលើការរៀបចំហេដ្ឋារចនាសម្ព័ន្ធនានាទាំងសោភ័ណភាពបរិក្ខាបច្ចេកទេសទំនើបៗនិងសេវាកម្មដ៏ល្អតាមស្តង់ដារអន្តរជាតិហើយលោកអ្នកឧកញ៉ាមានសុដ្ឋិនិយមថាមន្ទីរពេទ្យអន្តរជាតិអរៀនដា នឹងជួយផ្លាស់ប្តូរការគិតរបស់ប្រជាពលរដ្ឋខ្មែរឱ្យមកស្វែងរកសេវាកម្មសុខាភិបាលនៅក្នុងស្រុកវិញ។

តាមរយៈអនុស្សរណៈនៃការយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជានិងមន្ទីរពេទ្យអន្តរជាតិអរៀនដាបានផ្តល់ជូននូវអត្ថប្រយោជន៍ដ៏ពិសេសជូនដល់៖

១/ ថ្នាក់ដឹកនាំ ក្រុមគ្រួសារ និងបុគ្គលិករបស់ថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជា

២/ សមាជិក ក្រុមគ្រួសារ និងបុគ្គលិករបស់សមាជិកសមាគមឧកញ៉ាកម្ពុជា

៣/ បុគ្គលិក និងក្រុមគ្រួសាររបស់បុគ្គលិកនៃសមាគមឧកញ៉ាកម្ពុជា

ដោយទទួលបាននូវ៖

- ការបញ្ចុះតម្លៃ ៥០% លើកញ្ចប់ពិនិត្យសុខភាព
- ការបញ្ចុះតម្លៃ២០%លើគ្រប់សេវាពិនិត្យ និងព្យាបាលទាំងអស់ (លើកលែងតែសេវាជំងឺលំបាកមានកូន និងសេវាសង្គ្រោះបន្ទាន់តាមយន្តហោះពិសេស ២៤ម៉ោង)

ការផ្តល់ជូននេះមានរយៈពេល២ឆ្នាំនិងអាចប្រើប្រាស់បាននៅមន្ទីរពេទ្យអន្តរជាតិអរៀនដា,មន្ទីពហុព្យាបាល និងសម្ភព អរៀនដា, មន្ទីរពេទ្យ អយើតកោះពេជ្រ និងមន្ទីរព្យាបាល និងសម្ភព អយើតសែនសុខ។










## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីបញ្ចុះបឋមសិលាសាងសង់សារមន្ទីរសម្តេចព្រះព្រហ្មរតនមុនី ពិន សែម








នៅព្រឹកថ្ងៃព្រហស្បតិ៍ ១៣កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងពិធីបញ្ចុះបឋមសិលាសាងសង់សារមន្ទីរសម្តេចព្រះព្រហ្មរតនមុនី ពិន សែម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** ដោយកម្មវិធីនេះប្រព្រឹត្តទៅក្នុងបរិវេណវត្តរាជបូណ៌ ស្ថិតនៅសង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។

ចំពោះការសាងសង់សារមន្ទីរ **សម្តេចព្រះព្រហ្មរតនមុនី ពិន សែម** នឹងប្រើប្រាស់រយៈពេល២៤ខែ។ ក្នុងនោះដែរមានសប្បុរសជនជាថ្នាក់ដឹកនាំក៏ដូចជាសមាជិកសមាគមឧកញ៉ាកម្ពុជាចំនួន១២៣រូបបានចូលរួមបរិច្ចាគថវិកាដើម្បីប្រើប្រាស់សម្រាប់ការសាងសង់សារមន្ទីរនេះ។

សូមបញ្ជាក់ថាសារមន្ទីរ **សម្តេចព្រះព្រហ្មរតនមុនី ពិន សែម** ត្រូវបានកសាងឡើងក្នុងគោលបំណងពីរសំខាន់ៗ គឺទី១ ដើម្បីរក្សាសម្បត្តិវប្បធម៌រួមមាន បុរាណវត្ថុសាងពីថ្ម ស្ពាន់ សំរឹទ្ធ ទង់ដែង លង្ហិន ទេពរូប ព្រះពុទ្ធរូប និងគ្រឿងកុលាលភាជន៍នានាដែលមានអាយុកាលចាប់ពីសម័យបុរេប្រវត្តិរហូតដល់សម័យក្រោយអង្គរសរុបប្រមាណ ២៥៧៥វត្ថុហើយត្រូវបានសម្តេចព្រះព្រហ្មរតនមុនីខិតខំស្វែងរកនិងប្រមូលរក្សាទុកតាំងពីអំឡុងឆ្នាំ១៩៨០មក និងទី២គឺដើម្បីទាក់ទាញទេសចរណ៍ក្នុងខេត្តសៀមរាបបន្ថែមទៀតខណៈដែលវិស័យទេសចរណ៍ជាចលករមួយដ៏សំខាន់ក្នុងការរុញកំណើនសេដ្ឋកិច្ចជាតិនិងបង្កើតការងារសម្រាប់ប្រជាពលរដ្ឋ។ សារមន្ទីរនេះមានទីតាំងនៅក្នុងវត្តរាជបូណ៌ ដែលជាវត្តដ៏ចំណាស់មួយក្នុងចំណោមវត្តដទៃទៀតនៅក្នុងខេត្តសៀមរាបដែលស្ថិតនៅក្នុងក្រុងតាមដងស្ទឹងសៀមរាប អារាមនេះមានព្រះវិហារមួយដែលមានលក្ខណៈស្ថាបត្យកម្មល្អឯកនិងបានសាងសង់ឡើងក្នុងរាជព្រះបាទនរោត្តម។ នៅលើជញ្ជាំងព្រះវិហារផ្នែកខាងក្នុងមានសិល្បៈដ៏រស់រវើកល្អវិចិត្រគឺគំនូរបុរាណរឿង«រាមកេរ្តិ៍»ដែលជារឿងដ៏ល្បីល្បាញនៅអាស៊ីអាគ្នេយ៍និងត្រូវបានគូរនៅរវាងឆ្នាំ១៩២០-១៩២៤។

## អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ចូលរួមកិច្ចប្រជុំពេញអង្គលើកទី១នៃក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ក.ផ.ផ.)

នាព្រឹកថ្ងៃចន្ទ ២រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចូលរួមកិច្ចប្រជុំពេញអង្គលើកទី១នៃក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ក.ផ.ផ.) ក្រោមអធិបតីភាព ឯកឧត្តម សុខ សូកេន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធាន ក.ផ.ផ. ដែលមានការអញ្ជើញចូលរួមពីតំណាងស្ថាប័នក្រសួងពាក់ព័ន្ធនិងតំណាងវិស័យឯកជននានាៗដូចជាសមាគមឧកញ៉ាកម្ពុជាសភាពាណិជ្ជកម្មកម្ពុជា សមាគមនៃវិស័យទេសចរណ៍ សមាគមសណ្ឋាគារ តំណាងក្រុមហ៊ុនព្រលានយន្តហោះ ក្រុមហ៊ុន អ៊ែរអេស៊ាក្រុមហ៊ុនអង្គរអ៊ែរព្រមទាំងឯកឧត្តមលោកជំទាវលោកអ្នកឧកញ៉ាអ្នកឧកញ៉ាឧកញ៉ាលោកលោកស្រីដែលជាសមាជិកនៃក្រុមប្រឹក្សាភិបាល ក.ផ.ផ ក៏ដូចជាភាគីពាក់ព័ន្ធទាំងអស់នៅសណ្ឋាគារ Rosewood ។

គួររំលឹកថា តាមរយៈសេចក្តីសម្រេចលេខ១២៤ សសរ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានតែងតាំងសមាសភាពរបស់ ក.ផ.ផ. ដោយមានការចូលរួមជាសមាជិកពីតំណាងផ្នែករដ្ឋចំនួន ៧ក្រសួង/ស្ថាប័នពាក់ព័ន្ធ ព្រមទាំងផ្នែកឯកជនចំនួន ៧ស្ថាប័នផងដែរ និងមានតួនាទីជាយន្តការស្ថាប័នដែលមានលក្ខណៈអំណោយផល និងបើកទូលាយដោយអនុញ្ញាតឱ្យវិស័យឯកជនចូលរួមពេញលេញជាមួយរាជរដ្ឋាភិបាលដោយឈរលើគោលការណ៍ "រួមគិត រួមធ្វើ រួមទទួលខុសត្រូវ" ទាំងលើផ្នែកហិរញ្ញវត្ថុបច្ចេកទេសនិងគំនិតយោបល់ក្នុងការជំរុញការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាស្របតាមនិន្នាការទេសចរណ៍សាកលលោក និងតំបន់ដែលកំពុងមានការវិវត្តយ៉ាងលឿនដែលទាមទារឱ្យមានភាពបត់បែនខ្ពស់ ធានាឱ្យបាននូវនិរន្តរភាព បរិយាបន្ន និងភាពធន់នៃវិស័យទេសចរណ៍របស់កម្ពុជា។







## ពិធីចុះហត្ថលេខាលើចុះអនុស្សរណៈយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជា និង សារព័ត៌មាន ស៊ីស៊ីថាមស៍ (The Cambodia China Times)







នារសៀលថ្ងៃអង្គារ ទី២៣ ខែកក្កដា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោក គួន សំបូរ និពន្ធនាយកសារព័ត៌មាន ស៊ីស៊ីថាមស៍ ភាសាខ្មែរ បានចុះអនុស្សរណៈយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជា និង សារព័ត៌មាន ស៊ីស៊ីថាមស៍ (The Cambodia China Times) ក្នុងគោលបំណងផ្សព្វផ្សាយព័ត៌មានពីសមាគមឧកញ៉ាកម្ពុជាដើម្បីរួមចំណែកលើកកម្ពស់ឧត្តមភាពដ៏ឧត្តុង្គឧត្តម នៃគោរមងារឧកញ៉ាក្នុងការចូលរួមអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា។

អ្នកឧកញ៉ា ហ៊ុន ឡាក់ បានថ្លែងថា ស៊ីស៊ីថាមស៍ គឺជាស្ថាប័នព័ត៌មានដែលមានវិជ្ជាជីវៈត្រឹមត្រូវមានសក្តានុពលនៃការផ្សព្វផ្សាយទាំងភាសាខ្មែរ និងភាសាចិនដែលជាតម្រូវការរបស់សមាគមឧកញ៉ាកម្ពុជាក្នុងការជំរុញការផ្សព្វផ្សាយនានាក្នុងគោលដៅជំរុញការអភិវឌ្ឍន៍ប្រទេសកម្ពុជាតាមគោលបំណងរបស់សមាគមឧកញ៉ាកម្ពុជា។

ជាមួយគ្នានេះ លោក គួន សំបូរ និពន្ធនាយកសារព័ត៌មាន ស៊ីស៊ីថាមស៍ បានថ្លែងអំណរគុណដល់សមាគមឧកញ៉ាកម្ពុជាដែលមានជំនឿទុកចិត្តលើស្ថាប័នព័ត៌មាន ស៊ីស៊ីថាមស៍។ លោកបានចាត់ទុកអនុស្សរណៈ នៅថ្ងៃនេះនឹងជួយឱ្យការផ្សព្វផ្សាយរបស់ព័ត៌មាន ស៊ីស៊ីថាមស៍ កាន់តែមានភាពសំបូរបែប និងស៊ីជម្រៅចូលរួមលើកកម្ពស់ឧត្តមភាពដ៏ឧត្តុង្គឧត្តមនៃគោរមងារឧកញ៉ាក្នុងការចូលរួមអភិវឌ្ឍសង្គម។

## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំកិច្ចប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាល លើកទី៨ ដើម្បីពិនិត្យរបាយការណ៍និងវឌ្ឍនភាពការងារប្រចាំឆមាសទី១ ឆ្នាំ២០២៤



នារសៀលថ្ងៃព្រហស្បតិ៍ ៥រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំកិច្ចប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាលលើកទី៨ នាទីស្នាក់ការសមាគមឧកញ៉ាកម្ពុជាក្នុងសណ្ឋាគារភ្នំពេញដោយមានវត្តមានចូលរួមពីសំណាក់លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាអនុប្រធាន និងជាសមាជិកក្រុមប្រឹក្សាភិបាលចំនួន ៣០រូប។

ជាកិច្ចចាប់ផ្តើម លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានអង្គប្រជុំ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំទាំងមូលដែលបានចំណាយពេលដ៏មានតម្លៃចូលរួមកិច្ចប្រជុំដ៏មានសារៈសំខាន់នាថ្ងៃនេះ។ ជាកិច្ចបន្ទាប់ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការបានធ្វើបទបង្ហាញជូនអង្គប្រជុំទាំងមូលទៅតាមរបៀបវារៈនីមួយៗដោយសមាជិកអង្គប្រជុំបានចូលរួមជជែកពិភាក្សា និងផ្តល់ធាតុចូលសំខាន់ៗទៅលើរបៀបវារៈទាំងនោះយ៉ាងផុសផុល និងយកចិត្តទុកដាក់ជាទីបំផុត។

សម្រាប់កិច្ចប្រជុំវិសាមញ្ញលើកទី៨នេះមានរបៀបវារៈសំខាន់ៗដូចជា៖

១. ការប្រកាសអំពីសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលថ្មីចំនួន ១៣រូបដែលទើបជាប់ឆ្នោត

២. ការធ្វើបច្ចុប្បន្នភាពនៃពិធីសំណេះសំណាល និងពិសាភោជនាហារសាមគ្គីមហាគ្រួសារឧកញ៉ាកម្ពុជានាថ្ងៃទី២ ខែសីហា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី និងលោកជំទាវបណ្ឌិត**

៣. កិច្ចពិភាក្សាអំពីកម្មវិធីផ្គូផ្គងធុរកិច្ចកម្ពុជា-ថៃ នាដើមខែកញ្ញា ឆ្នាំ២០២៤ ខាងមុខ

៤. របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី២ និងប្រចាំឆមាសទី១ ឆ្នាំ២០២៤

៥. ពិភាក្សាបញ្ហាផ្សេងៗ













ជាលទ្ធផល កិច្ចប្រជុំបានសម្រេចឯកភាពលើរបៀបវារៈនីមួយៗដូចខាងក្រោម៖

របៀបវារៈទី១៖ លោកអ្នកឧកញ៉ាប្រធាននិងអង្គប្រជុំទាំងមូលបានមានប្រសាសន៍ស្វាគមន៍ចំពោះសមាជិកក្រុមប្រឹក្សាភិបាលថ្មីទាំង១៣រូបបន្ទាប់ពីបានឡើងណែនាំខ្លួនជូនអង្គប្រជុំព្រមទាំងបានប្តេជ្ញាចិត្តក្នុងការចូលរួមរាល់គ្រប់សកម្មភាពរបស់សមាគមក៏ដូចជាការចូលរួមទាំងកម្លាំងកាយកម្លាំងចិត្តធនធាននិងចំណេះដឹងដើម្បីជំរុញសមាគមឧកញ៉ាកម្ពុជាសម្រេចឱ្យបាននូវចក្ខុវិស័យ និងបេសកកម្មដែលបានកំណត់របស់សមាគមឧកញ៉ាកម្ពុជា។

របៀបវារៈទី២៖ អង្គប្រជុំបានពិនិត្យឃើញថា ការរៀបចំនានាបានប្រព្រឹត្តទៅតាមការគ្រោងទុកទាំងទីកន្លែងប្រារព្ធកម្មវិធី ការរៀបចំការសម្តែងទស្សនីយភាពសិល្បៈ និងពិធីការជាដើម។ បន្ថែមពីលើនេះ អង្គប្រជុំបានឯកភាពក្នុងការបង្កើតគណៈកម្មការ ២បន្ថែមទៀតដើម្បីជួយចាត់ចែង និងសម្របសម្រួលលើការងារនៃពិធីពិសាភោជនាអាហារសាមគ្គីរបស់សមាគមឧកញ៉ានាថ្ងៃទី២ សីហា ឆ្នាំ២០២៤ខាងមុខផងដែរ។

របៀបវារៈទី៣៖ អង្គប្រជុំបានឯកភាពក្នុងការរៀបចំកម្មវិធីផ្គូផ្គងធុរកិច្ចកម្ពុជា-ថៃនៅរាជធានីភ្នំពេញនាដើមខែកញ្ញា ឆ្នាំ២០២៤។

របៀបវារៈទី៤៖ អង្គប្រជុំបានពិនិត្យនិងឯកភាពទៅលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី២ និងប្រចាំឆមាសទី១ ឆ្នាំ២០២៤ របស់សមាគមឧកញ៉ាកម្ពុជាដោយអ្នកឧកញ៉ា ផៃ ហុកឈួន ប្រធានគណៈកម្មការរដ្ឋបាល និងហិរញ្ញវត្ថុ បានធ្វើបទបង្ហាញនូវចំនួនថវិកាដែលជាចំណូលចំណាយនិងអតិរេករបស់សមាគមឧកញ៉ាកម្ពុជាប្រចាំខែនីមួយៗផងដែរ។

ដោយសារតែរបៀបវារៈផ្សេងៗត្រូវបានពិភាក្សា និងឯកភាពរួចរាល់ លោកអ្នកឧកញ៉ាប្រធាន បានមានប្រសាសន៍ថ្លែងអំណរគុណសារជាថ្មីចំពោះអង្គប្រជុំទាំងមូលនិងបានផ្តល់អនុសាសន៍ល្អៗដល់អគ្គលេខាធិការដ្ឋានក្នុងការបំពេញការងារឱ្យបានល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាព។

កិច្ចប្រជុំបានបិទបញ្ចប់នៅវេលាម៉ោង១៨:៣០នាទីក្នុងកាលបរិច្ឆេទថ្ងៃខែឆ្នាំដដែលដោយទទួលបានលទ្ធផលផ្លែផ្កាក្រោមបរិយាកាសសប្បាយរីករាយ និងស្និទ្ធស្នាលបំផុត។

## ពិធីសំណេះសំណាល និងពិសាភោជនាហារសាមគ្គី នៃមហាគ្រួសារសមាគមឧកញ៉ាកម្ពុជានិង សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជានិងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត




រសៀលថ្ងៃសុក្រ ១៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២ ខែសីហា ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់អញ្ជើញជាអធិបតីនៅក្នុងពិធីសំណេះសំណាល និងពិសាភោជនាហារសាមគ្គី នៃមហាគ្រួសារសមាគមឧកញ៉ាកម្ពុជា និងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជានៅអគារ ដឹព្រេមៀ សេនធ័រ សែនសុខដោយមានការចូលរួមពី លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ឥស្សរជនជាន់ខ្ពស់ថ្នាក់ដឹកនាំក្រសួង-ស្ថាប័នឯកអគ្គរាជទូត-រដ្ឋទូត តំណាងស្ថានពាណិជ្ជកម្មជាតិ-អន្តរជាតិ និងវិស័យឯកជនសរុបប្រមាណ ១៣០០នាក់។

នៅក្នុងឱកាសដ៏មានសារៈសំខាន់នេះ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានរាយការណ៍ជូនអង្គពិធីទាំងមូលនូវសារតារសង្ខេបនៃសមាគមឧកញ៉ាកម្ពុជាដែលត្រូវបានបង្កើតឡើងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា ដោយមានចក្ខុវិស័យ និងបេសកកម្មច្បាស់លាស់ព្រមទាំងត្រូវបានប្រកាសជាផ្លូវការនា ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ និងត្រូវបានទទួលស្គាល់កម្រិតខ្ពស់បំផុតដោយព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្តីពីគោរមងារឧកញ៉ាហើយចាប់តាំងពីថ្ងៃបង្កើតជាផ្លូវការមកសមាគមឧកញ៉ាកម្ពុជាបានចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាលើកិច្ចការរៀបចំការតំណាងនិងកិច្ចការពារគោរមវន្តក៏ដូចជាសកម្មភាពនៃការជំរុញពាណិជ្ជកម្មនិងទាក់ទាញវិនិយោគក្នុងគោលបំណងបង្កើតការងារជូនប្រជាពលរដ្ឋកម្ពុជាតាមរយៈកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នជាតិ និងអន្តរជាតិ រួមទាំងការអមដំណើរថ្នាក់ដឹកនាំក្នុងបេសកកម្មធុរកិច្ចក្រៅប្រទេស និងសកម្មភាព

មនុស្សធម៌ជាច្រើនផ្សេងទៀតដើម្បីសម្រាលការលំបាករបស់ប្រជាពលរដ្ឋរងគ្រោះនានា។

ក្នុងពិធីដ៏មហោឡារិកនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ថ្លែងនូវសុន្ទរកថាគន្លឹះ ដោយ **សម្តេច** បានមានប្រសាសន៍លើកឡើងពីភារកិច្ចស្នូលរបស់សមាគមឧកញ៉ាកម្ពុជាក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១តាមរយៈការបង្កើននូវកម្មវិធីសកម្មភាពសេដ្ឋកិច្ចដែលជាកត្តាសំខាន់ដូចជាការបង្កើតការងារនិងឱកាសផ្សេងៗដើម្បីភាពរីកចម្រើនជីវភាពរបស់ប្រជាពលរដ្ឋ។ **សម្តេច** បានសង្កត់ធ្ងន់ថា សមាជិកទាំងអស់នៃសមាគមឧកញ៉ាកម្ពុជានិងវិនិយោគិនដែលកំពុងធ្វើធុរកិច្ចនៅកម្ពុជាបានដើរតួនាទីសំខាន់ណាស់នៅក្នុងការជំរុញសេដ្ឋកិច្ចប្រកបដោយចីរភាពនិងនិរន្តរភាព។ ជាមួយគ្នានេះតាមរយៈបេសកកម្មចម្បងៗរបស់សមាគមឧកញ៉ាកម្ពុជាដែលកន្លងមកបានចូលរួមចំណែកយ៉ាងសកម្មក្នុងសកម្មភាពសង្គមនិងសប្បុរសធម៌នានាជាពិសេសក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩។

**សម្តេចធិបតី**ក៏បានលើកឡើងថារាជរដ្ឋាភិបាលតែងគិតគូរពីសុខុមាលភាពរបស់វិនិយោគិនទាំងអស់ដោយយកចិត្តទុកដាក់ស្តាប់ជាប្រចាំនូវបញ្ហាប្រឈមដែលវិនិយោគិនលើកឡើងនិងបន្តពង្រឹងទំនាក់ទំនងជាមួយវិស័យឯកជនដើម្បីដោះស្រាយបញ្ហាដែលកើតឡើងថ្មីៗប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពដោយប្រកាន់ខ្ជាប់នូវគោលការណ៍ «គិតរួមគ្នាធ្វើសកម្មភាពរួមគ្នានិងទទួលខុសត្រូវរួមគ្នា»។ ក្នុងន័យនេះរាជរដ្ឋាភិបាលបានរៀបចំវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនជាប្រចាំហើយវេទិកាលើកទី១៩ កាលពីខែវិច្ឆិកា ឆ្នាំ២០២៣ កន្លងទៅនេះ ដោយបានអនុម័តកញ្ចប់វិធានការកែទម្រង់ជាក់ស្តែងជាច្រើនដើម្បីសម្រាលបន្ទុករបស់វិស័យឯកជន ។











ក្នុងឱកាសនេះដែរ **សម្តេចធិបតី** បានប្រកាសឱ្យអនុវត្តការទទួលយកក្រដាសប្រាក់ដាច់រហែក ទក់ ខូច ឬប្រឡាក់តិចតួចនៅក្របខណ្ឌទូទាំងប្រទេសតែម្តងដោយមិនមានការកាត់ថ្លៃសេវានោះទេ។ **សម្តេច** បានលើកទឹកចិត្តប្រជាពលរដ្ឋនិងគោរមវន្តជាឧកញ៉ាដែលសុទ្ធសឹងជាធុរជនទាំងអស់ជួយជំរុញការប្រើប្រាស់ប្រាក់រៀលរបស់ជាតិឱ្យបានច្រើនដែលជាការលើកកម្ពស់ប្រាក់រៀលផងនិងបង្ហាញពីការលើកតម្កើងអត្តសញ្ញាណជាតិផង។

**សម្តេចធិបតី** ក៏បានស្នើឱ្យសមាគមឧកញ៉ាកម្ពុជារួមគ្នាបង្កើនការអភិវឌ្ឍខេត្តនៅទិសព្វសានដើម្បីជំរុញសេដ្ឋកិច្ចនិងជំរុញការអភិវឌ្ឍនៅតាមខេត្តជាប់ព្រំដែនទាំង៤នេះឱ្យកាន់តែរឹងមាំជាពិសេសគឺដើម្បីរួមគ្នាថែរក្សាបូរណភាពទឹកដីដែលជាឧត្តមប្រយោជន៍ជាតិ។

ក្នុងពិធីដ៏វិសេសវិសាលនេះដែរ **សម្តេចមហាបវរធិបតី** បានផ្តល់កិត្តិយសបំពាក់មេដាយជាតូបការដល់គោរមវន្ត និងសប្បុរសជនជាច្រើនរូប ព្រមទាំងការថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាល និងសមាជិក នៃសមាគឧកញ៉ាកម្ពុជារួមទាំងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជាផងដែរ។























# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតីហ៊ុន ម៉ាណែត និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត











នាព្រឹកថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីបើកការដ្ឋានសាងសង់ «ព្រែកជីកហ្វូណនតេជោ» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត**។

ព្រែកជីកហ្វូណនតេជោ គឺជាគម្រោងមួយដ៏ធំមហិមានិងមានលក្ខណៈជាយុទ្ធសាស្ត្រពិសេសដែលសាងសង់ ឡើងក្នុងគោលដៅលើកកម្ពស់សកម្មភាពដឹកជញ្ជូនទំនិញ កសិផល និងភ្ញៀវទេសចរ គ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតរួមទាំងពង្រឹងឯករាជ្យភាពអធិបតេយ្យភាព និងពង្រីកឧត្តមភាពនៃការដឹកជញ្ជូនតាមផ្លូវទឹករបស់កម្ពុជាផ្ទាល់។

សូមបញ្ជាក់ថា ក្នុងនីតិកាលទី៧នេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដោយបានកំណត់ចក្ខុវិស័យប្រែក្លាយកម្ពុជាជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ ។ ក្នុងនោះការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងភស្តុភារកម្ម ជាពិសេសការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹកនិងគម្រោងផ្លូវនាវាចរណ៍ត្រូវបានចាត់ទុកជាអាទិភាពគន្លឹះមួយក្នុងចំណោមវិស័យសំខាន់ៗជាច្រើនទៀតនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ។

## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាង សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ជាមួយ លោកស្រី Mio Kawada អនុប្រធានអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO)



នាថ្ងៃអង្គារ ២កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាការងាររវាង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាមួយលោកស្រី Mio Kawadaអនុប្រធានអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) នៅវិមានសន្តិភាព។

ក្នុងឱកាសនៃជំនួបនេះ លោកស្រី Mio Kawada អនុប្រធានអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគនៅកម្ពុជា។ លោកស្រីបាន គោរពជម្រាបជូន **សម្តេចធិបតី** ថា នេះជាលើកទី២ដែលអង្គការ JETRO បានរៀបចំបេសកកម្មធុរកិច្ចនៅកម្ពុជា ដោយលើកនេះមានក្រុមហ៊ុនជប៉ុនចូលរួមចំនួន១៩ ដែលចាប់អារម្មណ៍ការវិនិយោគនៅកម្ពុជាក្នុងវិស័យផ្សេងៗរួមទាំងលើបច្ចេកវិទ្យាបៃតង និងឥណទានកាបូនតាមរយៈបច្ចេកវិទ្យាថ្មី និងទំនើបរបស់ជប៉ុន។

ជាមួយគ្នានេះ **សម្តេចធិបតី** បានស្វាគមន៍ការបន្តចាប់អារម្មណ៍របស់បណ្តាក្រុមហ៊ុនជប៉ុនក្នុងការស្វែងរកនូវឱកាសវិនិយោគ និងការផ្សារភ្ជាប់ទំនាក់ទំនងជាមួយដៃគូធុរកិច្ចនៅកម្ពុជា។ **សម្តេចធិបតី** បានសម្តែងនូវការគាំទ្រលើចំណាប់អារម្មណ៍របស់ក្រុមហ៊ុនជប៉ុនលើវិស័យថាមពលស្អាតនិងឥណទានកាបូនដែលមានសង្គតិភាពជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការធានានូវការអភិវឌ្ឍប្រកបដោយចីរភាពនិងការដាក់ចេញនូវទិសដៅជំរុញថាមពលស្អាតឱ្យបានដល់ ៧០% ត្រឹមឆ្នាំ២០៣០។ **សម្តេចធិបតី** ក៏បានណែនាំឱ្យបង្កើតក្រុមការងារដែលមានតំណាងក្រសួង-ស្ថាប័នកម្ពុជាពាក់ព័ន្ធដើម្បីសម្របសម្រួលជាមួយអង្គការJETROនិងក្រុមហ៊ុនជប៉ុនខាងលើក៏ដូចជាពិភាក្សាការងារបន្តលើបច្ចេកវិទ្យាបៃតង និងឥណទានកាបូន។

សូមបញ្ជាក់ថា បន្ទាប់ពីគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បានចូលរួមអមដំណើរ **សម្តេចធិបតី** ក្នុងដំណើរទស្សនកិច្ចទៅកាន់ប្រទេសជប៉ុន កាលពីចុងឆ្នាំ២០២៣ រួចមក សមាគមឧកញ៉ាកម្ពុជា បានបន្តធ្វើការជាមួយភាគីជប៉ុនជាហូរហែ ជាក់ស្តែង ចាប់ពីថ្ងៃទី៦-៧-៨ ខែសីហា ឆ្នាំ២០២៤ នេះ សមាគមឧកញ៉ាកម្ពុជា បានទទួល និងដឹកនាំគណៈប្រតិភូជប៉ុនចំនួន២៤រូបដែលអញ្ជើញមកបំពេញទស្សនកិច្ចធុរកិច្ចនៅកម្ពុជាចូលជួបសម្តែងការគួរសមសម្តេចធិបតីនាយករដ្ឋមន្ត្រី និងទស្សកិច្ចសិក្សានៅរោងចក្រនិងចំការអំពៅ ក្នុងខេត្តកំពង់ស្ពឺ, រោងចក្រ ខ្មែរ ប៊ែវើរីជីស ក្នុងទីក្រុងភ្នំពេញ និងកសិដ្ឋានផលិតស្រូវ និងជីកំប៉ុស្តិ៍ ក្នុងខេត្តព្រៃវែង។

ស្របពេលដែល សមាគមឧកញ៉ាកម្ពុជា ក៏បានសហការជាមួយអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) ប្រចាំកម្ពុជា ព្រមទាំងភ្នាក់ងាររុករកលំហអាកាសជប៉ុន (JAXA) រៀបចំ «សន្និសីទស្តីពីការបង្កើតកិច្ចនិង

លំហអាកាសទំនើបចុងក្រោយបំផុតរបស់ប្រទេសជប៉ុន» ព្រមទាំងកម្មវិធី «ជំនួបផ្គូផ្គងធុរកិច្ចកម្ពុជា-ជប៉ុន» ក្រោមប្រធានបទ៖ «ធុរកិច្ចឥណទានកាបូន និងបរិយាកាសវិនិយោគនៅកម្ពុជា» ផងដែរ។

















## សន្និសីទស្តីពីការបង្កើតកិច្ចសហការរួមគ្នាកម្ពុជា-ជប៉ុន ចាប់យកឱកាសធុរកិច្ចនៃឥណទានកាបូននៅកម្ពុជា ដោយប្រើប្រាស់បច្ចេកវិទ្យាបៃតង និងលំហអាកាសទំនើបចុងក្រោយបំផុតរបស់ប្រទេសជប៉ុន ព្រមទាំងកម្មវិធី "ជំនួបផ្គូផ្គងធុរកិច្ចកម្ពុជា-ជប៉ុន" ក្រោមប្រធានបទ៖ "ធុរកិច្ចឥណទានកាបូន និងបរិយាកាសវិនិយោគនៅកម្ពុជា"

សមាគមឧកញ៉ាកម្ពុជាដោយមានកិច្ចសហការពីអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន(JETRO)ប្រចាំកម្ពុជា ព្រមទាំងភ្នាក់ងាររុករកលំហអាកាសជប៉ុន (JAXA) នឹងរៀបចំ ״សន្និសីទស្តីពីការបង្កើតកិច្ចសហការរួមគ្នា កម្ពុជា-ជប៉ុនចាប់យកឱកាសធុរកិច្ចនៃឥណទានកាបូននៅកម្ពុជាដោយប្រើប្រាស់បច្ចេកវិទ្យាបៃតងនិងលំហអាកាសទំនើបចុងក្រោយបំផុតរបស់ប្រទេសជប៉ុន״ នាព្រឹកថ្ងៃពុធទី៧ខែសីហាឆ្នាំ២០២៤ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឯកឧត្តម UENO Atshushi ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា, លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាព្រមទាំងភ្ញៀវកិត្តិយសនិងវាគ្មិនជាអ្នកជំនាញការនិងធុរជនក្នុងប្រទេសកម្ពុជានិងជប៉ុនជាច្រើនរូបទៀត។





















ព្រមទាំងកម្មវិធី «ជំនួបផ្គូផ្គងធុរកិច្ចកម្ពុជា-ជប៉ុន» ក្រោមប្រធានបទ៖ «ធុរកិច្ចឥណទានកាបូន និងបរិយាកាសវិនិយោគនៅកម្ពុជា» នាពេលរសៀលដែលនឹងប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ព្រមទាំងថ្នាក់ដឹកនាំជាតំណាងក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ក៏ដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ព្រមទាំងថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជា និងធុរជនជប៉ុនផងដែរសរុបប្រមាណ ៣០០នាក់។

សូមជម្រាបជូនថា នេះគឺជាព្រឹត្តិការណ៍លើកដំបូងនៅកម្ពុជាដែលនឹងមានការចូលរួមពីវាគ្មិនកម្ពុជា - ជប៉ុន ជាអ្នកជំនាញផ្នែកធុរកិច្ច បរិស្ថាន កសិកម្ម ឧស្សាហកម្ម និងបច្ចេកវិទ្យា មកធ្វើការចែករំលែកចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងធុរកិច្ចឥណទានកាបូនដោយប្រើប្រាស់បច្ចេកវិទ្យាបៃតង និងផ្កាយរណប ដើម្បីជាមូលដ្ឋានសម្រាប់ធុរជនកម្ពុជាចាប់យកឱកាសក្នុងប្រតិបត្តិការអាជីវកម្មថ្មីតាមរយៈការបង្កើត និងលក់ឥណទានកាបូនក្នុងវិស័យធុរកិច្ចបៃតង។

សូមបញ្ជាក់ថា កម្មវិធីនេះទទួលបានការឧបត្ថម្ភគាំទ្រពី Chip Mong Group ក្រុមហ៊ុន Khmer Beverages និងធនាគារ SBI Ly Hour ផងដែរ។

## សមាគមឧកញ៉ាកម្ពុជា និង JETRO ប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីបង្កើតនូវកាលានុវត្តភាព ធុរកិច្ចរវាងធុរជនជប៉ុន និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជា

នាព្រឹកថ្ងៃពុធ ៣កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយថ្នាក់ដឹកនាំ ក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជាបានជួបពិភាក្សាការងារជាមួយលោកស្រី Mio Kawada អនុប្រធានអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។

ក្នុងឱកាសនេះដែរលោកអ្នកឧកញ៉ាលីយ៉ុងផាត់បានថ្លែងថាជប៉ុនគឺជាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនខណៈដែលវិនិយោគិនជប៉ុនទទួលបានទំនុកចិត្តខ្ពស់និងបានរួមចំណែកជាច្រើនដល់ការជំរុញសកម្មភាពពាណិជ្ជកម្មនិងវិនិយោគដែលរួមចំណែកក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិហើយកម្ពុជាពិតជាត្រូវការភាគីជប៉ុនដូចដែលសម្តេចធិបតីនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា សូមវិនិយោគិនជប៉ុនចាត់ទុកប្រទេសកម្ពុជាថាជាផ្ទះរបស់ខ្លួន ។

លោកអ្នកឧកញ៉ាប្រធានបានសង្កត់ធ្ងន់ថាសមាគមឧកញ៉ាកម្ពុជាសូមស្វាគមន៍ជានិច្ចនូវកិច្ចសហប្រតិបត្តិការនានារវាងស្ថាប័នទាំងពីរសំដៅជំរុញក៏ដូចជាទាក់ទាញការវិនិយោគបន្ថែមទៀតនៅកម្ពុជា។































ទន្ទឹមនឹងនេះ លោកស្រី Mio Kawada បានលើកឡើងថា ក្នុងនាមលោកស្រីផ្ទាល់រួមជាមួយថ្នាក់ដឹកនាំ JETRO ពិតជាមានភាពកក់ក្ដៅ និងរីករាយបំផុតដែលទទួលបានការស្វាគមន៍យ៉ាងខ្លាំងពីសមាគមឧកញ៉ាកម្ពុជា ដែលបានរៀបចំជំនួបជាមួយសម្ដេចធិបតីកាលពីម្សិលមិញ ក៏ដូចជាសន្និសីទ និងកម្មវិធីផ្គូផ្គងធុរកិច្ចរវាងធុរជន នៃប្រទេសទាំងពីរផងដែរ។លោកស្រីបានបញ្ជាក់ថានេះជាកាលានុវត្តភាពដ៏សំខាន់ក្នុងការផ្សព្វផ្សាយអំពីកម្ពុជាទៅកាន់មជ្ឈដ្ឋានធុរកិច្ចជប៉ុន ខណៈដែលមានវិនិយោគិនជប៉ុនច្រើនៗឡើងបានចាប់អារម្មណ៍អំពីប្រទេសកម្ពុជា ជាក់ស្ដែងកាលពីឆ្នាំមុនមានក្រុមហ៊ុនតែ៧ប៉ុណ្ណោះដែលមកចូលរួមសន្និសីទនេះប៉ុន្តែសម្រាប់ឆ្នាំ២០២៤មានក្រុមហ៊ុនដល់ទៅ១៩បានចូលរួម។

សូមបញ្ជាក់ថាថ្នាក់ដឹកនាំនៃស្ថាប័នទាំងពីរបានឯកភាពគ្នាថានឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ដើម្បីបង្កើតនូវកាលានុវត្តភាពនៃការចាប់ដៃគូរវាងធុរជនជប៉ុន និង សមាជិកនៃសមាគមឧកញ៉ាកម្ពុជា នាពេលអនាគត។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជា និងក្រុមហ៊ុន SAGRI Corporation Private Limited ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម




នាព្រឹកថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤ នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនសុី ភ្នំពេញ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជា និងក្រុមហ៊ុន SAGRI Corporation Private Limited ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម ព្រមទាំងឯកឧត្តម UENO Atshushi ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រជប៉ុនប្រចាំនៅកម្ពុជាដោយពិធីនេះបានធ្វើឡើងក្នុង សន្និសីទស្តីពីការបង្កើតកិច្ចសហការរួមគ្នាកម្ពុជា-ជប៉ុនចាប់យកឱកាសធុរកិច្ចនៃឥណទានកាបូននៅកម្ពុជាដោយប្រើប្រាស់បច្ចេកវិទ្យាបៃតង និងលំហអាកាសទំនើបចុងក្រោយបំផុតរបស់ប្រទេសជប៉ុន៉ុ”។

សូមបញ្ជាក់ថា SAGRI Corporation Private Limited គឺជាក្រុមហ៊ុនដ៏លេចធ្លោមួយរបស់ប្រទេសជប៉ុន ដែលធ្វើអាជីវកម្មលើការដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ និងសន្តិសុខស្បៀងជាមួយនឹងបច្ចេកវិទ្យាស្ពេនពីចម្ងាយដ៏ទំនើបទៅលើដីកសិកម្ម និងការផ្តល់នូវយន្តការដោះស្រាយលើផលប៉ះពាល់សង្គមរួមទាំងអាជីវកម្មលើឥណទានកាបូបផងដែរ។

តាមរយៈអនុស្សរណៈនៃការយោគយល់គ្នានេះ ស្ថាប័នទាំងពីរនឹងបំពេញកិច្ចសហប្រតិបត្តិការជាមួយគ្នាលើការចែករំលែកនូវចំណេះដឹង ការសិក្សាស្រាវជ្រាវទៅលើគម្រោងឥណទានកាបូនដើម្បីជាប្រយោជន៍ដល់កសិករកម្ពុជា ព្រមទាំងការផ្គូផ្គងធុរកិច្ចរវាងសមាជិក នៃសមាគមឧកញ៉ាកម្ពុជាដែលមានចំណាប់អារម្មណ៍ក្នុងការវិនិយោគលើឥណទានកាបូនជាមួយក្រុមហ៊ុន SAGRI ផងដែរ។








SEEKING CARBON CREDIT BUSINESS
OPPORTUNITIES IN CAMBODIA USING CUTTING EDGE GREEN
AND SPACE TECHNOLOGIES FROM JAPAN
ទាញយកឱកាសធុរកិច្ចនៃឥណទានកាបូន
នៅកម្ពុជា ដោយប្រើប្រាស់បច្ចេកវិទ្យាបៃតង និង លំហអាកាស
ទំនើបចុងក្រោយបំផុតរបស់ប្រទេសជប៉ុន

## ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន ថ្លែងលើកទឹកចិត្តទៅកាន់បណ្ដាអ្នកវិនិយោគិនជប៉ុន សូមបន្តចូលរួមសហការជាមួយសមាគមឧកញ៉ាកម្ពុជាដើម្បីជំរុញការផ្លាស់ប្តូរព័ត៌មានរបស់ភាគីទាំងពីរឱ្យបានកាន់តែល្អប្រសើរ



ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានថ្លែងលើកទឹកចិត្តទៅកាន់បណ្ដាអ្នកវិនិយោគិនជប៉ុន សូមបន្តចូលរួមសហការជាមួយសមាគមឧកញ៉ាកម្ពុជាដើម្បីជំរុញការផ្លាស់ប្តូរព័ត៌មានរបស់ភាគីទាំងពីរឱ្យបានកាន់តែល្អប្រសើរ។

ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត បានបន្ថែមថាតាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំនិងទូលំទូលាយជាមួយសមាគមឧកញ៉ាកម្ពុជានឹងបង្កើនឱកាសវិនិយោគបន្ថែមទៀតដើម្បីជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចដល់កម្រិតខ្ពស់រវាងកម្ពុជាជប៉ុនលើគ្រប់វិស័យ។

នៅក្នុងឱកាសអញ្ជើញជាអធិបតីក្នុងសន្និសីទស្តីពីការបង្កើតកិច្ចសហការរួមគ្នាកម្ពុជាជប៉ុនចាប់យកឱកាសធុរកិច្ចនៃឥណទានកាបូននៅកម្ពុជាដោយប្រើប្រាស់បច្ចេកវិទ្យាបៃតង និងលំហរអាកាសទំនើបចុងក្រោយបំផុតរបស់ប្រទេសជប៉ុននាព្រឹកថ្ងៃទី៧ខែសីហាឆ្នាំ២០២៤ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថាកម្ពុជាគឺជាផ្ទះដែលពេញដោយស្នាមញញឹម និងឱកាសវិនិយោគជាច្រើនសម្រាប់មិត្តធុរជនជាតិអន្តរជាតិដែលមានបំណងជួយឱ្យកម្ពុជាមានភាពស្អាត កម្ពុជាមានភាពបៃតងហើយរក្សាបានភាពស្អាត និងភាពបៃតងនេះជារៀងរហូតទៅ។











ជាមួយគ្នានេះឯកឧត្តមរដ្ឋមន្ត្រីបានកោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់ធុរជនគ្រប់រូបដែលបានរួមចំណែកក្នុងការធ្វើឱ្យមានកំណើនសេដ្ឋកិច្ចនិងប្រកបដោយភាពបៃតងស្អាតនិងចីរភាពជាមួយគ្នានេះការនាំមកនូវបច្ចេកវិទ្យាគឺជាកត្តាជំរុញឱ្យល្បឿននៃការវិនិយោគវិវឌ្ឍទៅបានលឿន និងឆាប់រហ័ស ប៉ុន្តែយ៉ាងណាត្រូវតែគិតមុនគេទៅដល់ប្រាក់ចំណូលនិងផលប្រយោជន៍របស់ប្រជាកសិករខ្មែរដែលស្របនឹងគោលនយោបាយជាតិឆ្ពោះទៅជាប្រទេសមានចំណូលខ្ពស់កម្រិតមធ្យមនៅឆ្នាំ២០៥០ និងក្លាយជាប្រទេសអព្យាក្រឹតកាបូនតាមរយៈការបង្កើនគម្របព្រៃឈើ៦០ % នៅឆ្នាំ ២០៥០។

សូមរំលឹកថា សន្និសីទនេះត្រូវបានរៀបចំដោយសមាគមឧកញ៉ាកម្ពុជា អង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ប្រទេសជប៉ុន និងទីភ្នាក់ងាររុករកអវកាសជប៉ុន (JAXA) ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម Atsushi Ueno ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា និងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧញ៉ាកម្ពុជា ក្នុងគោលបំណងបង្កើនការយល់ដឹងដល់ធុរជនតាមរយៈបច្ចេកវិទ្យា និងបង្កើននូវឱកាសអាជីវកម្មថ្មីៗដើម្បីបង្កើតប្រភពចំណូលមួយផ្សេងទៀតតាមរយៈការលក់ឥណទានកាបូន និងពង្រីកអាជីវកម្មតាមរបៀបបៃតង និងនិរន្តរភាព។
















## ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ផ្តល់កិត្តិយសអញ្ជើញថ្លែងសុន្ទរកថាគន្លឹះអំពីបរិយាកាសវិនិយោគនៅកម្ពុជាក្នុងជំនួបធុរកិច្ចកម្ពុជា-ជប៉ុន



ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានផ្តល់កិត្តិយសអញ្ជើញថ្លែងសុន្ទរកថាគន្លឹះក្នុងជំនួបធុរកិច្ចកម្ពុជាជប៉ុនដែលសហការរៀបចំឡើងដោយសមាគមឧកញ៉ាកម្ពុជានិងអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) ក្នុងគោលបំណងផ្សព្វផ្សាយអំពីកាលានុវត្តភាពវិនិយោគ ព្រមទាំងគោលនយោបាយលើកទឹកចិត្តលើធុរកិច្ចឥណទានកាបូន ក៏ដូចជាផ្គូផ្គងធុរកិច្ចរវាងវិនិយោគិនកម្ពុជា និងជប៉ុនផងដែរកាលពីរសៀលថ្ងៃពុធ ទី៧ ខែសីហា ឆ្នាំ២០២៤ ដោយបានផ្តោតសំខាន់លើបរិយាកាសវិនិយោគនិងលក្ខខណ្ឌអំណោយផលនៃស្ថានភាពធុរកិច្ចនៅកម្ពុជា។

ជាមួយគ្នានេះ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានផ្តល់កិត្តិយសប្រគល់នូវលិខិតថ្លែងអំណរគុណចំពោះវាគ្មិនកិត្តិយសព្រមទាំងតំណាងក្រុមហ៊ុនដែលជាដៃគូឧបត្ថម្ភក្នុងជំនួបធុរកិច្ចកម្ពុជា-ជប៉ុន ដែលសហការរៀបចំឡើងដោយសមាគមឧកញ៉ាកម្ពុជា និងអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) ព្រមទាំងភ្នាក់ងាររុករកលំហអាកាសជប៉ុន (JAXA)។

សូមជម្រាបថា វាគ្មិនកិត្តិយសទាំង៣រូបមានសមាសភាពដូចជា៖
១) ឯកឧត្តម សួន សុផល អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
២) ឯកឧត្តម សំ សិទ្ធិស័ក្តិ អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម
៣) លោក ចុង ប៊ូ អនុប្រធាននាយកដ្ឋានបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។













HYATT
REGENCY










Organizer
In special partnership
Sponsors

## អ្នកឧកញ៉ា ហ៊ិន ឡាក់ អគ្គលេខាធិការ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ទទួលជួបសម្តែងការគួរសមជាមួយគណៈប្រតិភូតំណាងអង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុន (Japan External Trade Organization-JETRO) ប្រចាំនៅកម្ពុជា

នារសៀលថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹង ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ិន ឡាក់ អគ្គលេខាធិការ តំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានទទួលជួបសម្តែងការគួរសមជាមួយគណៈប្រតិភូតំណាងអង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុន(Japan External Trade Organization – JETRO) ប្រចាំនៅកម្ពុជាដឹកនាំដោយ លោកស្រី Haruta Marisa ដែលទើបបញ្ចប់បេសកកម្មការងារនៅកម្ពុជា និងបានធ្វើការណែនាំលោក Wakabayashi Kohei ជាប្រធានអង្គការ JETRO ដែលទើបទទួលបានការតែងតាំងភារកិច្ចថ្មីមកជំនួសលោកស្រី ។

ក្នុងឱកាសជំនួបនេះអ្នកឧកញ៉ាអគ្គលេខាធិការរួមទាំងសហការីនៃសមាគមឧកញ៉ាកម្ពុជាបានថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការកន្លងមករវាងស្ថាប័នទាំងពីរព្រមទាំងបានសម្តែងការស្វាគមន៍ចំពោះលោក Wakabayashi Kohei ប្រធានអង្គការ JETRO ដែលទើបទទួលភារកិច្ចថ្មី និងបានលើកទឹកចិត្តឱ្យស្ថាប័នទាំងពីរបន្តពង្រឹងទំនាក់ទំនងល្អក៏ដូចជាបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែប្រសើរឡើងថែមមួយកម្រិតទៀតក្នុងការជំរុញនិងលើកកម្ពស់សកម្មភាពពាណិជ្ជកម្មនិងវិនិយោគរវាងកម្ពុជានិងជប៉ុនជាពិសេសលើវិស័យធុរកិច្ចបៃតង។

ជាកិច្ចឆ្លើយតប លោកស្រី Haruta Marisa និងលោក Wakabayashi Kohei បានថ្លែងអំណរគុណចំពោះការស្វាគមន៍យ៉ាងកក់ក្តៅក៏ដូចជាការគាំទ្រកន្លងមករបស់សមាគមឧកញ៉ាកម្ពុជាក្នុងកិច្ចសហការនានាក្នុងគោលដៅនាំមកនូវផលប្រយោជន៍រួមសម្រាប់សេដ្ឋកិច្ច និងពាណិជ្ជកម្មនៃប្រទេសទាំងពីរ ជាពិសេសការគាំទ្រលើការរៀបចំ «សន្និសីទនិងជំនួបផ្គូផ្គងធុរកិច្ចស្តីពីការបង្កើតកិច្ចសហការរួមគ្នាកម្ពុជា–ជប៉ុនក្នុងវិស័យធុរកិច្ចឥណទានកាបូន» កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤ កន្លងមកថ្មីៗនេះ។

ជាចុងបញ្ចប់ភាគីទាំងពីរបានបង្ហាញការប្តេជ្ញាចិត្តក្នុងការពង្រឹងកិច្ចសហការបន្ថែមដើម្បីស្វែករកឱកាសវិនិយោគដល់ធុរជនកម្ពុជា-ជប៉ុនតាមរយៈការសហការរៀបចំព្រឹត្តិការណ៍ធុរកិច្ចជាបន្តបន្ទាប់ទៀត។











ជំនួបសម្តែងការគួរសម និងពិភាក្សាការងារ
Courtesy Visit and Next Plan Discussion

# អ្នកឧកញ៉ា សៀ ឫទ្ធី អនុប្រធាន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ទទួលជួបការសម្តែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម Zaheeruddin Babar Thaheem ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថានប្រចាំព្រះរាជាណាចក្រកម្ពុជា





នាព្រឹកថ្ងៃសុក្រ ១១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹង ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤ អ្នកឧកញ៉ា សៀ ឫទ្ធី អនុប្រធាន និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អម ដោយ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងក្រុមការងារអគ្គលេខាធិការដ្ឋាន បានទទួលជួបការសម្តែង ការគួរសម និងពិភាក្សាការងារ ជាមួយ ឯកឧត្តម Zaheeruddin Babar Thaheem ឯកអគ្គរដ្ឋទូត នៃសាធារណ រដ្ឋអ៊ិស្លាមប៉ាគីស្ថានប្រចាំព្រះរាជាណាចក្រកម្ពុជានៅទីស្នាក់ការសមាគមឧកញ៉ាកម្ពុជានាសណ្ឋាគារភ្នំពេញ។

គោលបំណងនៃជំនួបនេះ គឺដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័នទាំងពីរ និងពិភាក្សាលើការជំរុញ ទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា និងប៉ាគីស្ថាន ឱ្យកាន់តែឈានខ្ពស់មួយកម្រិតទៀត។

អ្នកឧកញ៉ាអនុប្រធានបានសម្តែងការស្វាគមន៍ចំពោះវត្តមានរបស់ឯកឧត្តមឯកអគ្គរដ្ឋទូតនិងបង្ហាញការគាំទ្រ ចំពោះគំនិតផ្តួចផ្តើមក្នុងការពង្រឹង និងពង្រីកសកម្មភាពធុរកិច្ច និងពាណិជ្ជកម្មនៃប្រទេសទាំងពីរ ជាពិសេសការធ្វើ យ៉ាងណាឱ្យមានការផ្សារភ្ជាប់ទ្វេដងរវាងសហគមន៍ធុរកិច្ចកម្ពុជា និងប៉ាគីស្ថាន។ អ្នកឧកញ៉ាអនុប្រធានបានជម្រាប ជូន ឯកឧត្តមឯកអគ្គរដ្ឋទូត អំពីប្រវត្តិ សកម្មភាព ចក្ខុវិស័យ និងបេសកកម្មរបស់សមាគមឧកញ៉ាកម្ពុជាផងដែរ។

ជាមួយគ្នានេះ ឯកឧត្តមឯកអគ្គរដ្ឋទូត បានវាយតម្លៃខ្ពស់ចំពោះតួនាទីដ៏សំខាន់របស់សមាគម ដែលជាបណ្តុំនៃធុរជន និងវិនិយោគិនមកពីពហុវិស័យ និងជាកម្លាំងចលករមួយរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ។ ឯកឧត្តមឯកអគ្គរដ្ឋទូត ក៏បានលើកឡើងអំពីសក្តានុពលនៃប្រទេសប៉ាគីស្ថាន ដែលមានចំនួនប្រជាជនច្រើនជាង ២៤១,៥ លាននាក់ ជាទីផ្សារមួយដ៏ធំនៅក្នុងតំបន់ និងមានផលិតផលនាំចេញសំខាន់ៗ ដូចជា អង្ករ កប្បាស សម្លៀកបំពាក់ និងឱសថ ជាដើម ចំណែកផលិតផលនាំចូល មានដូចជា ប្រេងឆៅ ប្រេងដូង ឧស្ម័នធម្មជាតិ ដែកថែប និងគ្រឿងអេឡិកត្រូនិច ជាដើម។

យោងតាមលទ្ធផលនៃជំនួបនេះស្ថាប័នទាំងពីរបានព្រមព្រៀងលើការគ្រោងរៀបចំជំនួបពាណិជ្ជកម្មរវាងធុរជនកម្ពុជា និងប៉ាគីស្ថាន នាពេលខាងមុខ ដោយផ្តោតលើវិស័យអាទិភាពនៃប្រទេសទាំងពីរ។












## អ្នកឧកញ៉ា ហ៊ិន ឡាក់ រួមជាមួយអ្នកឧកញ៉ា លី សាំងឡេង និងឧកញ៉ា អាន ឌីណា ទទួលជួប ពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រុមហ៊ុន PCA Global Associates ដែលវិនិយោគលើវិស័យបច្ចេកវិទ្យា

នារសៀលថ្ងៃអង្គារ ១កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ិន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយអ្នកឧកញ៉ា លី សាំងឡេង សមាជិកក្រុមប្រឹក្សាភិបាល និងឧកញ៉ា អាន ឌីណា សមាជិក នៃសមាគមឧកញ៉ាកម្ពុជា ព្រមទាំងលោក យឿម ប៉ូរ៉ាន អគ្គលេខាធិការរង បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយនឹងតំណាងក្រុមហ៊ុន PCA Global Associates ដែលមានមូលដ្ឋាននៅក្នុងប្រទេសឥណ្ឌា។

គោលបំណងនៃកិច្ចប្រជុំនេះគឺដើម្បីពិភាក្សាពីកិច្ចសហប្រតិបត្តិការធុរកិច្ច និងស្វែងរកដៃគូពាណិជ្ជកម្មនៅប្រទេសកម្ពុជារបស់ក្រុមហ៊ុន PCA Global Associates ដែលជាក្រុមហ៊ុនបច្ចេកវិទ្យាឈានមុខគេនៅប្រទេស ឥណ្ឌា និងកំពុងបំពេញអាជីវកម្មលើដំណោះស្រាយក្នុងវិស័យអប់រំ, ហិរញ្ញវត្ថុ, សុខាភិបាល, ការរៀបចំទីក្រុងវៃឆ្លាត, ការគ្រប់គ្រងទូទៅ និងការអភិវឌ្ឍគេហទំព័រ និងបណ្ដាញសង្គមនានាជាដើម។

តាមរយៈកិច្ចប្រជុំនេះ ភាគីទាំងពីរបានឯកភាពក្នុងការសហប្រតិបត្តិការគ្នាបន្ថែមទៀត និងបន្តជំរុញភាពជាដៃគូធុរកិច្ចរវាងក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មានដ៏ធំនេះជាមួយនឹងសមាជិកសមាគមឧកញ៉ាកម្ពុជាខណៈដែលមានសមាជិកជាច្រើនកំពុងប្រកបអាជីវកម្មលើវិស័យបច្ចេកវិទ្យា និងវិស័យពាក់ព័ន្ធជាច្រើនទៀត។









# ប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងដំណើរទស្សនកិច្ចទីក្រុងសៀមិន សាធារណរដ្ឋប្រជាមានិតចិន








នាព្រឹកថ្ងៃទី៧ខែកញ្ញាឆ្នាំ២០២៤គណៈប្រតិភូកម្ពុជាក្រោមកិច្ចដឹកនាំដោយផ្ទាល់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អមដំណើរដោយសមាជិកសមាគមឧកញ៉ាកម្ពុជា បានបំពេញដំណើរទស្សនកិច្ចឆ្ពោះទៅកាន់ទីក្រុងសៀមិនសាធារណរដ្ឋប្រជាមានិតចិនដែលបេសកកម្មនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយនិងធ្វើបច្ចុប្បន្នភាពអំពីបរិយាកាសវិនិយោគ និងកាលានុវត្តភាពធុរកិច្ចនៅកម្ពុជាក្នុងព្រឹត្តិការណ៍ទាក់ទាញនិងជំរុញវិនិយោគក្នុងពិព័រណ៍អន្តរជាតិចិនលើកទី២៤។ជាការកត់សម្គាល់ក្នុងឱកាសនេះ ឯកឧត្តម Wang Wenbin ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជាក៏បានឆ្លៀតពេលវេលាដ៏មានតម្លៃអញ្ជើញជូនដំណើរគណៈប្រតិភូកម្ពុជាថែមទៀតផង។

បន្ទាប់ពីបានអញ្ជើញដល់ទីក្រុងសៀមិននាល្ងាចថ្ងៃដដែលនេះអ្នកឧកញ៉ាហ៊ុនឡាក់ព្រមទាំងប្រតិភូសមាគមឧកញ៉ាកម្ពុជា បានចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងពិធីទទួលទានអាហារ និងពិភាក្សាការងារជាមួយលោក Wei Keliang ប្រធានគណៈកម្មាធិការទីក្រុងសៀមិននៃក្រុមប្រឹក្សាសភានយោបាយប្រជាជនចិន។ក្នុងកិច្ចពិភាក្សាការងារនេះក៏បានការអញ្ជើញចូលរួមពីរដ្ឋបាលទីក្រុងសៀមិន ព្រមទាំងវិនិយោគិនកម្ពុជា និងចិនចូលរួមជាច្រើនរូបផងដែរ។

ក្នុងឱកាសនេះមិនត្រឹមតែមានការពិភាក្សាអំពីកិច្ចសហប្រតិបត្តិការការងារ រវាងរដ្ឋាភិបាលនិងរដ្ឋាភិបាលប៉ុណ្ណោះទេប៉ុន្តែថ្នាក់ដឹកនាំទាំងពីរក៏បានរៀបចំការផ្គូផ្គងវិស័យឯកជនដែលមកពីសមាគមឧកញ៉ាកម្ពុជានិងវិនិយោគិនចិនដើម្បីស្វែងយល់ពីគ្នាលើកិច្ចការងារវិនិយោគនិងសកម្មភាពពាណិជ្ជកម្មជាដើម។
















**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ដឹកនាំគណៈប្រតិភូកម្ពុជា អញ្ជើញទទួលទានអាហារ និងពិភាក្សាការងារជាមួយ លោកបណ្ឌិត Mohammed Al Zarooni ប្រធានអង្គការតំបន់សេរីពិភពលោក (World Free Zone Organization) និងជានាយកប្រតិបត្តិនៃតំបន់សេដ្ឋកិច្ចរួមបញ្ចូលឌូបៃ (Dubai Integrated Economic Zones)**

ក្នុងដំណើរអញ្ជើញបំពេញការងារនៅប្រទេសចិន នៅព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា អញ្ជើញទទួលទានអាហារ និងពិភាក្សាការងារជាមួយលោកបណ្ឌិត Mohammed Al Zarooni ប្រធានអង្គការតំបន់សេរីពិភពលោក (World Free Zone Organization) និងជានាយកប្រតិបត្តិនៃតំបន់សេដ្ឋកិច្ចរួមបញ្ចូលឌូបៃ (Dubai Integrated Economic Zones)។

ជំនួបនោះ ក៏មានការអញ្ជើញចូលរួមពីសំណាក់លោកបណ្ឌិត James Zhan ប្រធានសម្ព័ន្ធសកលនៃតំបន់សេដ្ឋកិច្ចពិសេស និងលោក Juma Al Matrooshi នាយកប្រតិបត្តិក្រុមហ៊ុន Dubai Silicon Oasis ក៏ដូចជាប្រតិភូនៃសមាគមឧកញ៉ាកម្ពុជាផងដែរ។

ជំនួបដែលជាការឆ្លៀតពីរបៀបវារៈការងារដ៏មមាញឹកនេះបានធ្វើឡើងដើម្បីពិភាក្សាលើរបៀបរបបនិងភាពខុសប្លែកគ្នានៃការរៀបចំបង្កើតតំបន់ពាណិជ្ជកម្មសេរី (Free-Trade Zone) ព្រមទាំងវិធីសាស្ត្រផ្សេងៗដែលអាចធានាឱ្យការទាក់ទាញក្រុមហ៊ុននានាពិចារណាបណ្ដាក់ទុនវិនិយោគ ការរៀបចំបង្កើតតំបន់ FTZ និងការវិនិយោគក្នុងតំបន់ផ្ទាល់សម្រាប់ជំរុញដំណើរការ នៃតំបន់ពាណិជ្ជកម្មសេរី។

បន្ទាប់មកពីទៀត ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមពិធិបើក "ពិព័រណ៍អន្តរជាតិចិនលើកទី២៤ សម្រាប់ការវិនិយោគ និងពាណិជ្ជកម្ម" (The 24th China International Fair for Investment and Trade) ឬ (CIFIT លើកទី២៤) ដែលរៀបចំឡើងនៅទីក្រុងសៀមិន ខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

ពិធីបើកពិព័រណ៍នាឱកាសនេះត្រូវបានរៀបចំឡើងក្រោមអធិបតីភាពឯកឧត្តម He Lifeng ឧបនាយករដ្ឋមន្ត្រី និងជាសមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិនព្រមទាំងមានការចូលរួមយ៉ាងកុះករពីថ្នាក់ដឹកនាំធំៗរបស់សាធារណរដ្ឋប្រជាមានិតចិនឥស្សរជនជាន់ខ្ពស់នៃអេមីរ៉ាតអារ៉ាប់រួម ទីភ្នាក់ងារជំរុញការវិនិយោគបរទេស អង្គការអន្តរជាតិ សហគ្រាស និងតំណាងធុរកិច្ច មកពីប្រមាណ ៣០ប្រទេសជុំវិញពិភពលោក។












ថ្លែងក្នុងពិធីបើកនេះដែរ ឯកឧត្តម ស៊ុន ចាន់ថុល បានមានប្រសាសន៍ថា កិច្ចការវិនិយោគ និងពាណិជ្ជកម្ម ជាក្បាលម៉ាស៊ីនជំរុញឱ្យមានការបង្កើតបច្ចេកវិទ្យាការងារនិងសសរស្តម្ភនៃស្ថិរភាពសេដ្ឋកិច្ច។ក្នុងន័យនេះតាមរយៈ ការវិនិយោគកម្ពុជាអាចកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ពាសពេញផ្ទៃប្រទេសទ្រទ្រង់លើភាពរីកចម្រើននៃធុរកិច្ច ឧស្សាហកម្មដើម្បីកំណើនសេដ្ឋកិច្ចជាតិក៏ដូចជាការនាំមកនូវបច្ចេកវិទ្យាថ្មីៗដែលនឹងជួយសម្រួលដល់ការរស់នៅផង ដែរ។ ជាងនេះទៅទៀត តាមរយៈពាណិជ្ជកម្ម កម្ពុជាអាចចូលរួមផ្លាស់ប្តូរកម្លាំងពលកម្ម ដែលអាចបង្កើតការងារ ការ ផ្លាស់ប្តូរជំនាញ ព្រមទាំងបង្កើនចំណងនៃការជឿទុកចិត្ត និងការគោរពគ្នាទៅវិញទៅមករវាងប្រជាជាតិនានានៅលើ សកលលោក។

ជាថ្មីម្តងទៀតតាមរយៈពិព័រណ៍អន្តរជាតិ CIFIT នេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានបង្ហាញគោលបំណង របស់កម្ពុជាដែលកំពុងស្វែងរកមធ្យោបាយថ្មីនៃកិច្ចសហប្រតិបត្តិការនិងការវិនិយោគនៅក្នុងវិស័យដូចជាបច្ចេកវិទ្យា ថាមពលកកើតឡើងវិញ និងការអភិវឌ្ឍប្រកបដោយចីរភាព។

សូមបញ្ជាក់ថាព្រឹត្តិការណ៍ព័រណ៍អន្តរជាតិចិនសម្រាប់ការវិនិយោគនិងពាណិជ្ជកម្មនេះមិនត្រឹមតែបង្ហាញអំពី សារៈសំខាន់នៃកម្លាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោកតាមរយៈការលើកកម្ពស់ឱកាសវិនិយោគនិងពាណិជ្ជកម្ម ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគូសបញ្ជាក់អំពីតួនាទីយ៉ាងសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការជំរុញកំណើន ប្រកបដោយចីរភាព។

លុះវេលារសៀលថ្ងៃអាទិត្យ ទី៨ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធាន ទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុញ្ញាតជូនប្រតិភូក្រុមហ៊ុន Wanli Stone ដឹកនាំដោយលោក Zou Peng ចូល ជួបពិសាអាហារ និងពិភាក្សាការងារជាមួយគណៈប្រតិភូកម្ពុជាដែលកំពុងបំពេញបេសកកម្មនៅទីក្រុងសៀមិន ខេត្ត ហ្វ៊ូជៀន នៃសាធារណរដ្ឋប្រជាមានិតចិន។

សូមបញ្ជាក់ថា បច្ចុប្បន្នក្រុមហ៊ុន Wanli Stone គឺជាក្រុមហ៊ុនមួយដែលកំពុងវិនិយោគនៅក្នុងខេត្តកំពង់ស្ពឺ នៃព្រះរាជាណាចក្រកម្ពុជាលើមុខសញ្ញាអាជីវកម្មថ្មម៉ាប ឬថ្មក្រានីត។ តាមរយៈជំនួបនេះ ក្រុមហ៊ុនបានបង្ហាញអំពី ផែនការរបស់ខ្លួនក្នុងការពង្រីកការវិនិយោគបន្ថែមទៀតក្នុងប្រទេសកម្ពុជា ពិសេសនឹងពិនិត្យលទ្ធភាពវិនិយោគ លើ ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសផងដែរ។

## អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងវេទិកាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងពាណិជ្ជកម្មនៃ RCEP ដែលជាផ្នែកមួយនៃបេសកកម្មក្នុងទីក្រុងសៀមិន

នាព្រឹកថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៤ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ក្រោមការដឹកនាំរបស់អ្នកឧកញ៉ា ហ៊ុន ឡាក់ បានចូលរួមក្នុងវេទិកាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មនៃ RCEP ខណៈដែល ឯកឧត្តម សួន សុផល អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា (គ.វ.ក.) និងជាអ្នកចូលរួមគូសវាសឯកសារកំណត់វិសាលភាពសម្រាប់ប្រើប្រាស់ក្នុងការចរចាជំពូកស្តីពីវិនិយោគក្រោមកិច្ចព្រមព្រៀង RCEP កាលពីឆ្នាំ២០១១ បានអញ្ជើញជាវាគ្មិនកិត្តិយសក្នុងវេទិកានេះផងដែរ  ក្នុងគោលបំណងចែករំលែកនូវទស្សនាទានក៏ដូចជាបទពិសោធនៃការចរចាច្រើនជុំរហូតដល់ឆ្នាំ២០១៤ជាមួយវាគ្មិននៃប្រទេសហត្ថលេខីនិងសហគមន៍ធុរកិច្ចដែលបានចូលរួមពិព័រណ៌អន្តរជាតិចិនសម្រាប់ការវិនិយោគ និងពាណិជ្ជកម្ម។

ឯកឧត្តមបានគូសបញ្ជាក់អំពីផ្លែផ្កាដែលព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងតែប្រមូលផលពីកិច្ចព្រមព្រៀងដ៏មានឧត្តមប្រយោជន៍មួយនេះដោយរាប់បញ្ចូលប៉ុន្តែមិនកម្រិតត្រឹមសកម្មភាពពាណិជ្ជកម្ម និងវិនិយោគ។  បន្ថែមពីនេះឯកឧត្តមក៏បានឆ្លៀតយកឱកាសនៃវេទិកាខាងលើផ្សព្វផ្សាយអំពីបច្ចុប្បន្នភាពថ្មីនៃបរិស្ថានធុរកិច្ចព្រមទាំងសក្តានុពល និងកាលានុវត្តភាពវិនិយោគទៅកាន់អ្នកចូលរួមផងដែរ។ គួរជម្រាបជូនផងដែរថា RCEP គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគីដ៏ធំមួយក្នុងប្រវត្តិសហសម័យរបស់ពិភពលោកដែលមានវិសាលភាពគ្របដណ្តប់ផលិតក្នុងស្រុកសរុប និងប្រជាជនសកលប្រមាណ៣០%។











## គណៈប្រតិភូកម្ពុជាចុះទស្សនកិច្ចមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិក្រុងសៀមិន (Xiamen International Convention and Exhibition Center)











ក្នុងឱកាសបំពេញបេសកកម្មនៅលើទឹកដីនៃសាធារណរដ្ឋប្រជាមានិតចិន គណៈប្រតិភូកម្ពុជា ដឹកនាំដោយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កាលពីថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៤ បានចុះទស្សនកិច្ចមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិក្រុងសៀមិន (Xiamen International Convention and Exhibition Center) ក្រោយពីបានចូលរួម "ពិព័រណ៍អន្តរជាតិចិនលើកទី២៤ សម្រាប់ការវិនិយោគ និងពាណិជ្ជកម្ម" (The 24th China International Fair for Investment and Trade) ឬ (CIFIT លើកទី២៤) ដែលរៀបចំឡើងនៅទីក្រុងសៀមិន ខេត្តហ្វូជៀនរួចមក។

ព្រឹត្តិការណ៍ពិព័រណ៍អន្តរជាតិចិនសម្រាប់ការវិនិយោគនិងពាណិជ្ជកម្មនេះមានការចូលរួមយ៉ាងច្រើនកុះករពីថ្នាក់ដឹកនាំសំខាន់ៗឥស្សរជនជាន់ខ្ពស់ទីភ្នាក់ងារជំរុញការវិនិយោគបរទេសអង្គការអន្តរជាតិសហគ្រាសនិងតំណាងធុរកិច្ចមកពីប្រមាណ៣០ប្រទេសជុំវិញពិភពលោកដែលមិនត្រឹមតែបង្ហាញអំពីសារៈសំខាន់នៃកម្លាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោកតាមរយៈការលើកកម្ពស់ឱកាសវិនិយោគ និងពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគូសបញ្ជាក់អំពីតួនាទីយ៉ាងសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការជំរុញកំណើនប្រកបដោយចីរភាព។

សូមបញ្ជាក់ថា គណៈប្រតិភូកម្ពុជាក្រោមការដឹកនាំដោយផ្ទាល់ពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានេះបានអញ្ជើញមាតុភូមិនិវត្តន៍មកដល់ព្រះរាជាណាចក្រកម្ពុជាវិញកាលពីយប់ថ្ងៃអង្គារ ទី៩ ខែកញ្ញា ឆ្នាំ២០២៤ ក្រោយបំពេញដំណើរទស្សនកិច្ចក្នុងក្រុងសៀមិន និងរដ្ឋធានីប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ ទទួលបានលទ្ធផលជោគជ័យប្រកបដោយផ្លែផ្កាពីការចូលរួមក្នុងព្រឹត្តិការណ៍កិច្ចប្រជុំទ្វេភាគី កិច្ចពិភាក្សាការងារ និងការផ្គូផ្គងធុរកិច្ចជាដើម។

ជាការកត់សម្គាល់ ក្នុងដំណើរមាតុភូមិនិវត្តន៍នេះ ឯកឧត្តម Wang Wenbin ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជាក៏បានឆ្លៀតពេលវេលាដ៏មានតម្លៃអញ្ជើញទទួលដំណើរត្រឡប់មកកម្ពុជាវិញរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងប្រតិភូកម្ពុជាផងដែរ។















## ថ្នាក់ដឹកនាំក៏ដូចជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបបានអញ្ជើញចូលរួមក្នុងកម្មវិធីពិសេស Gala Dinner នៃព្រឹត្តិការណ៍ Gumball 3000 x Chip Mong in Cambodia នៅមុខប្រាសាទបាយ័ន ខេត្តសៀមរាប

លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាថ្នាក់ដឹកនាំក៏ដូចជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបបានអញ្ជើញចូលរួមក្នុងកម្មវិធីពិសេស Gala Dinner នៅមុខប្រាសាទបាយ័ននាខេត្តសៀមរាបដែលបានប្រារព្ធធ្វើឡើងនៅរាត្រីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ ដើម្បីជាកិច្ចស្វាគមន៍ចំពោះប្រតិភូព្រមទាំងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិដែលបានធ្វើដំណើរមកចូលរួមព្រឹត្តិការណ៍ Gumball 3000 x Chip Mong in Cambodia ។

សូមបញ្ជាក់ថាព្រឹត្តិការណ៍នេះទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាក្រោមការចង្អុលបង្ហាញពីសំណាក់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**នាយករដ្ឋមន្ត្រីដោយមានក្រសួងទេសចរណ៍ដឹកនាំសម្រប សម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសគឺការសហការជាមួយក្រុមហ៊ុន ជីប ម៉ុង គ្រុប ក្នុងការរៀបចំព្រឹត្តិការណ៍នេះឡើង ក្នុងគោលបំណងលើកស្ទួយកិត្យានុភាពជាតិ និងវិស័យទេសចរណ៍ ជាពិសេសបង្កើនការផ្សព្វផ្សាយយុទ្ធនាការ «ទស្សនាសៀមរាប២០២៤» ព្រមទាំងដើម្បីប្រមូលថវិកាបរិច្ចាគជូនមន្ទីរពេទ្យកុមារអង្គរ ខេត្តសៀមរាប ដែលទទួលបានទឹកប្រាក់សរុបចំនួន ៤៥ម៉ឺនដុល្លារ និងជាឱកាសជំរុញការវិនិយោគ ពាណិជ្ជកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ចផងដែរខណៈដែលគណៈប្រតិភូដែលចូលរួមក្នុងព្រឹត្តិការណ៍នេះមានជាង៤០% សុទ្ធតែជាពាណិជ្ជករធំៗ ដែលនឹងជួបពិភាក្សាផ្នែកធុរកិច្ចជាមួយពាណិជ្ជករ ក្នុងស្រុកដើម្បីទាក់ទាញការវិនិយោគមកកាន់កម្ពុជា នាពេលខាងមុខ។









## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវ ព្រមទាំងថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមពិធីបើកពិព័រណ៍អាពាហ៍ពិពាហ៍ប្រចាំឆ្នាំ២០២៤

នាថ្ងៃសុក្រ ទី២០ ខែកញ្ញា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវព្រមទាំងថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមពិធីបើកពិព័រណ៍អាពាហ៍ពិពាហ៍ប្រចាំឆ្នាំ២០២៤ ក្រោមអធិបតីភាព **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** នៅមជ្ឈមណ្ឌល ដឹ ព្រេមៀ សេនធ័រ សែនសុខ។

មហាព្រឹត្តិការណ៍ពិព័រណ៍អាពាហ៍ពិពាហ៍លើកទី១ ប្រចាំឆ្នាំ២០២៤ ធំបំផុតមិនធ្លាប់មាននៅកម្ពុជា ដែលជួបជុំនូវក្រុមហ៊ុនផ្តល់សេវាកម្មរៀបចំពិធីមង្គលការដ៏សម្បូរបែប រួមមានទាំងសម្អាងការ ចុងភៅ ពិធីការ ការតុបតែង ថតរូបភេសជ្ជៈ គ្រឿងអលង្ការ និងសេវាកម្មពាក់ព័ន្ធជាច្រើននិងរួមគ្នាប្រមូលផ្តុំគ្រប់សេវាកម្មអាពាហ៍ពិពាហ៍ទាំងអស់មកដាក់តាំងបង្ហាញពីផលិតផលសេវាកម្មនីមួយៗក្នុងថ្ងៃតែមួយរយៈពេលបីថ្ងៃចាប់ពីថ្ងៃទី២០ដល់ថ្ងៃទី២២ខែកញ្ញា នៅមជ្ឈមណ្ឌល ដឹ ព្រេមៀ សែនធ័រ សែនសុខ រាជធានីភ្នំពេញ។














## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំសមាជិកចូលរួមពិធីកាន់បិណ្ឌទី៤ នៅវត្តកែវមុនីរស្មី ហៅវត្ត កន្ទួត ស្ថិតនៅភូមិកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ

នាព្រឹកថ្ងៃសៅរ៍ ៤រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៤ ដែលជាថ្ងៃកាន់បិណ្ឌទី៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជា បានចូលរួមពិធីបុណ្យកាន់បិណ្ឌ ៤ នៅវត្តកែវមុនីរស្មី (ហៅវត្ត កន្ទួត) ភូមិកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ឯកឧត្តម ប៊ិន ត្រឈៃ ប្រធានក្រុមការងារចុះជួយស្រុកឱរ៉ាល់ ឯកឧត្តម ជាម ច័ន្ទសោភ័ណ អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ រួមជាមួយក្រុមការងារ អាជ្ញាធរដែនដី ព្រមទាំងបងប្អូនប្រជាពុទ្ធបរិស័ទចំណុះជើងវត្តកែវមុនីរស្មីចូលរួមយ៉ាងច្រើនកុះករ។




















នាឱកាសនោះលោកអ្នកឧកញ៉ាប្រធាននិងសមាជិកសមាគមឧកញ៉ាកម្ពុជាបានចូលរួមបច្ច័យក្នុងការចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុងអារាមនេះដោយមានទឹកប្រាក់សរុបចំនួន ២៧លានរៀល និង៤៩០០ដុល្លារអាម៉េរិកដោយបច្ច័យទាំងនេះជាសទ្ធាពីថ្នាក់ដឹកនាំ និងសមាជិកដូចមានរាយនាមខាងក្រោមនេះ៖

១. បច្ច័យរបស់សមាគមឧកញ៉ាកម្ពុជា ចំនួន ៥លានរៀល

២. លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ចំនួន ១០លានរៀល

៣. អ្នកឧកញ៉ា រតនៈ សម្បត្តិ ចំនួន ៨លានរៀល

៤. ឧកញ៉ា មៀម វណ្ណៈ ចំនួន ៤លានរៀល

៥. អ្នកឧកញ៉ា តុល លន ចំនួន ៥០០ដុល្លារ

៦. អ្នកឧកញ៉ា លី សាំងឡេង ចំនួន ៥០០ដុល្លារ

៧. អ្នកឧកញ៉ា អ៊ីន ក្ងួត ចំនួន ៥០០ ដុល្លារ

៨. ឯកឧត្តម ឆាយ សុធា ចំនួន ២០០ដុល្លារ

៩. អ្នកឧកញ៉ា ទីវ ម៉េងហ៊ុយ ចំនួន ៥០០ ដុល្លារ

១០. អ្នកឧកញ៉ា ហេង បូរិន ចំនួន ៥០០ ដុល្លារ

១១. ជំទាវឧកញ៉ា ស៊ន សុទ្ធី និងជំទាវឧកញ៉ា ជា ឃីន ចំនួន ៥០០ដុល្លារ

១២. ជំទាវអ្នកឧកញ៉ា គី ម៉ានេ ចំនួន ២០០ដុល្លារ

១៣. ឧកញ៉ា ញឹក ផន ចំនួន ៥០០ដុល្លារ

១៤. ឧកញ៉ា លឹម ហ៊ាវពុទ្ធ ចំនួន ១០០០ដុល្លារ

ក្នុងឱកាសដ៏ប្រពៃនេះលោកអ្នកឧកញ៉ាប្រធានបានមានមតិសំណេះសំណាលក៏ដូចជាថ្លែងអំណរគុណចំពោះសមាជិកដែលបានចំណាយពេលវេលា និងចូលរួមជាបច្ច័យក្នុងវិស័យព្រះពុទ្ធសាសនាដើម្បីចាប់មគ្គផលតាមសទ្ធារៀងខ្លួនក្នុងពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌដែលជាបុណ្យបែបព្រះពុទ្ធសាសនាដ៏មានសារៈសំខាន់ និងប្រកបដោយអត្ថន័យដែលប្រជាពុទ្ធបរិស័ទកម្ពុជាតែងប្រណិប័តន៍យ៉ាងខ្ជាប់ខ្ជួនជារៀងរហូតមក។

# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ចាត់តាំង អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចូលរួមបេសកកម្មទាក់ទាញ និងជំរុញវិនិយោគនៅសហរដ្ឋអាមេរិក និងកាណាដា

យោងតាមសំណើពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា ធ្វើជាតំណាងលោកអ្នកឧកញ៉ាប្រធាន ដើម្បីដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលមានសមាសភាពដូចជា ជំទាវអ្នកឧកញ៉ា គួន ធីតា, ឧកញ៉ា លី សុភាព ឧកញ៉ា អាន ឪណា, ឧកញ៉ា ភិរម្យ វិចិត្រដារ៉ា, ឧកញ៉ា ឈឹម បញ្ញា, ឧកញ៉ា សុង សារ៉ន និង ឧកញ៉ា លីវ យុងថៃ, ចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចូលរួមបេសកកម្មទាក់ទាញ និងជំរុញវិនិយោគនៅសហរដ្ឋអាម៉េរិក និងកាណាដា ចាប់ពីថ្ងៃទី២២ ខែកញ្ញា ដល់ថ្ងៃទី២ ខែតុលា ឆ្នាំ២០២៤។

សូមបញ្ជាក់ថា បេសកកម្មនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយក៏ដូចជាផ្តួងធុរកិច្ច និងធ្វើបច្ចុប្បន្នភាពអំពីកាលានុវត្តភាពវិនិយោគលើវិស័យកសិកម្ម,កសិ-ឧស្សាហកម្ម,ទេសចរណ៍,សុខាភិបាលនិងថាមពលជូនធុរជននៅក្នុងប្រទេសទាំងពីរព្រមទាំងទាក់ទាញវិនិយោគិនដែលមានសក្តានុពលឱ្យមកបណ្តាក់ទុនវិនិយោគនៅកម្ពុជាឱ្យកាន់តែច្រើនឡើងថែមទៀត។





## អ្នកឧកញ៉ា ហ៊ុន ឡាក់ ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងសហព័ន្ធស្រូវអង្ករកម្ពុជាជាមួយនឹងក្រុមហ៊ុន Otis McAllister Inc









ក្នុងថ្ងៃដំបូងនៃបេសកកម្មលើទឹកដីសហរដ្ឋអាម៉េរិក នាព្រឹកថ្ងៃអាទិត្យ ទី២២ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អមដោយអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា ឯកឧត្តម បួន សារៈមុន្នី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ឯកឧត្តម សុខ ខាវណ្ណា រដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែនិងថាមពល និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀតបានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងសហព័ន្ធស្រូវអង្ករកម្ពុជា តំណាងដោយ ឧកញ៉ា សុង សារ៉ន ប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធ ជាមួយនិងក្រុមហ៊ុន Otis McAllister Inc. តំណាងដោយ លោក Patrick Murphy អនុប្រធានប្រតិបត្តិទទួលបន្ទុកផ្នែកបញ្ជាទិញអង្ករ និងគ្រាប់ធញ្ញជាតិ។

នាព្រឹកថ្ងៃអាទិត្យ ទី២២ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អមដោយអ្នកឧកញ៉ា ហ៊ុន ឡាក់, ឯកឧត្តម បួន សារៈមុន្នី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ឯកឧត្តម សុខ ខាវណ្ណ រដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត បានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងសហព័ន្ធស្រូវអង្ករកម្ពុជា តំណាងដោយ ឧកញ៉ា សុង សារ៉ន ប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធ ជាមួយនិងក្រុមហ៊ុន Otis McAllister Inc. តំណាងដោយ លោក Patrick Murphy អនុប្រធានប្រតិបត្តិទទួលបន្ទុកផ្នែកបញ្ជាទិញអង្ករ និងគ្រាប់ធញ្ញជាតិ។











## ប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងជំនួបពិភាក្សាលើប្រធានបទ“បច្ចុប្បន្នភាពនៃបរិយាកាសវិនិយោគនៅកម្ពុជា”

នាព្រឹកថ្ងៃចន្ទ ទី២៣ ខែកញ្ញា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ និងប្រតិភូសមាគមឧកញ៉ាកម្ពុជា បានចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងជំនួបពិភាក្សាលើប្រធានបទ «បច្ចុប្បន្នភាពនៃបរិយាកាសវិនិយោគនៅកម្ពុជា» ក្រោមការសម្របសម្រួលពី សភាពាណិជ្ជកម្មទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ ដោយមានការចូលរួមពីគណៈប្រតិភូធុរជនមកពីវិស័យពាក់ព័ន្ធដឹកនាំដោយលោក Crisostomo G. Ibarra ទីប្រឹក្សាផ្នែកច្បាប់ នៃការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជាក្នុងរដ្ឋកាលីហ្វ័រញ៉ា។

គណៈប្រតិភូកម្ពុជាបានទទួលការស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់សភាពាណិជ្ជកម្មទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូដែលជាម្ចាស់ផ្ទះនិងបានជជែកពិភាក្សាផ្លាស់ប្ដូរយោបល់ចែករំលែកបទពិសោធន៍លើបច្ចុប្បន្នភាពនៃការធ្វើពាណិជ្ជកម្មទាំងនៅកម្ពុជា និងនៅក្នុងទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូផ្ទាល់។ ចំពោះគោលដៅចម្បងនៃជំនួបពិភាក្សានេះ គឺដើម្បីបង្ហាញពីឱកាសនៃការវិនិយោគនៅកម្ពុជា ក៏ដូចជាក្របខណ្ឌគោលនយោបាយវិនិយោគថ្មីៗ វិធីសាស្ត្រគាំទ្រអាជីវកម្មនិងការត្រៀមខ្លួនដើម្បីបម្រើវិនិយោគិនឱ្យបានទាន់ពេលរបស់កម្ពុជាដែលជាប្រទេសមានទីតាំងយុទ្ធសាស្ត្រនៅចំកណ្ដាលអាស៊ាន។មួយផ្នែកទៀតគោលដៅនៃជំនួបនេះសំដៅសម្របសម្រួលទំនាក់ទំនងរវាងសហរដ្ឋអាម៉េរិកកាណាដាជាមួយនឹងក្រុមហ៊ុនក្នុងស្រុករបស់កម្ពុជាដើម្បីកំណត់អត្តសញ្ញាណដៃគូពាណិជ្ជកម្មដែលមានសក្ដានុពល។









ក្នុងកិច្ចពិភាក្សានេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានរំលេចអំពីសក្តានុពលនានារបស់ព្រះរាជាណាចក្រកម្ពុជា ដោយសង្កត់ធ្ងន់លើសុខសន្តិភាពនិងស្ថិរភាពនយោបាយលំនឹងម៉ាក្រូសេដ្ឋកិច្ចកម្លាំងពលកម្មវ័យក្មេងដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងត្រៀមរួចរាល់សម្រាប់បរិវត្តកម្មឌីជីថល ហេដ្ឋារចនាសម្ព័ន្ធអន្តរមធ្យោបាយដែលបាននឹងកំពុងអភិវឌ្ឍន៍ឱ្យកាន់តែមានភាពសម្បូរបែប និងប្រទាក់ក្រឡា។

បន្ថែមពីនោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានលើកឡើងអំពីការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាដល់ការរីកលូតលាស់នៃវិស័យធុរកិច្ចឯកជនដោយមានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសេនាធិការច្រកចេញចូលតែមួយក្នុងការសម្របសម្រួលជាមួយនឹងបែបបទនៃការវិនិយោគដែលមានភាពបត់បែនសំដៅលើកកម្ពស់បរិយាកាសធុរកិច្ចឱ្យកាន់តែមាន ជីវភាព ភាពទាក់ទាញ ភាពអំណោយផលខ្ពស់ និងអនុគ្រោះបំផុតសម្រាប់វិនិយោគិនបរទេសផងដែរ។
















## ប្រតិភូសមាគមឧកញ៉ាកម្ពុជា បន្តចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ក្នុងឱកាសជួបពិភាក្សាការងារ និងទទួលទានអាហារថ្ងៃត្រង់ធុរកិច្ច ជាមួយគណៈប្រតិភូក្រុមប្រឹក្សាតំបន់ឈូងសមុទ្រ (Bay Area Council - BAC)











នាវេលាថ្ងៃត្រង់ ថ្ងៃចន្ទ ទី២៣ ខែកញ្ញា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ និងប្រតិភូសមាគមឧកញ៉ាកម្ពុជា បានចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញជួបពិភាក្សាការងារ និងទទួលទានអាហារថ្ងៃត្រង់ធុរកិច្ច ជាមួយគណៈប្រតិភូក្រុមប្រឹក្សាតំបន់ឈូងសមុទ្រ (Bay Area Council - BAC) ដឹកនាំដោយ លោក Sean Randolph នាយកជាន់ខ្ពស់វិទ្យាស្ថានសេដ្ឋកិច្ចក្រុមប្រឹក្សាតំបន់ឆ្នេរ នៃសម្ព័ន្ធវិទ្យាសាស្ត្រ និងនវានុវត្តន៍តំបន់ឆ្នេរ និងដោយមានការចូលរួមផងដែរពី លោកស្រី Maryam Muduroglu នាយិកាពិធីការ នៃសាលាក្រុងសាន់ហ្វ្រាន់ស៊ីស្កូ ដើម្បីបន្តពាំនាំនូវបច្ចុប្បន្នភាពនៃបរិយាកាសវិនិយោគនៅកម្ពុជាជូនដល់វិនិយោគិនឯកជនពីក្រុមហ៊ុនធំៗមួយចំនួនដែលកំពុងវិនិយោគក្នុងក្រុងសាន់ហ្វ្រាន់ស៊ីស្កូដោយមានរៀបចំរបៀបវារៈដែលអនុញ្ញាតឱ្យវិស័យឯកជនកម្ពុជាដែលមានសមាសភាពពីសមាគមឧកញ៉ា និងធុរជនអាម៉េរិក បានជួបពិភាក្សាការងារ បង្កើតបណ្តាញទំនាក់ទំនង និងផ្គូផ្គងធុរកិច្ចផងដែរ។

កិច្ចពិភាក្សានាឱកាសនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីបង្ហាញជូនវិស័យឯកជនអំពីវឌ្ឍនភាពថ្មីៗនៃសក្តានុពល និងបរិយាកាសវិនិយោគនៅកម្ពុជា ពិសេសគោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភាដែលជារាជរដ្ឋាភិបាលគាំទ្រធុរកិច្ចនិងការវិនិយោគឯកជន។ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក្នុងនាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាសេនាធិការច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាល ក៏បានបង្ហាញអំពីការត្រៀមលក្ខណៈរួចរាល់ក្នុងការសម្របសម្រួលរាល់កិច្ចការងារវិនិយោគរបស់វិស័យឯកជននៅកម្ពុជាដែលនឹងធានាបាននូវបរិយាកាសវិនិយោគប្រកបដោយភាពបត់បែន អំណោយផល និងអនុគ្រោះបំផុត។ យ៉ាងណាមិញចំពោះទំនាក់ទំនងទ្វេភាគីតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានិងក្រុមប្រឹក្សាតំបន់ឈូងសមុទ្រភាគីទាំងពីររំពឹងថានឹងអាចពិនិត្យលទ្ធភាពនិងឱកាសរួមគ្នាក្នុងបង្កើតកិច្ចសហប្រតិបត្តិការនានាដើម្បីពង្រឹង និងពង្រីកទំនាក់ទំនងឱ្យកាន់តែល្អប្រសើរពិសេសលើវិស័យដឹកជញ្ជូនតាមផ្លូវសមុទ្រ និងកំពង់ផែ។

## ជំនួបពិភាក្សាការងាររវាងឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងថ្នាក់ដឹកនាំក្រុមហ៊ុន Levi Strauss & Co

កាលពីរសៀលថ្ងៃចន្ទ ទី២៣ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជារួមមានពីក្រសួងស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ដើម្បីជួបពិភាក្សាការងារជាមួយលោក Jeff Hogue ប្រធានផ្នែកនិរន្តរភាព និងសហការី តំណាងក្រុមហ៊ុន Levi Strauss&Coដែលជាក្រុមហ៊ុនសម្លៀកបំពាក់លំដាប់ពិភពលោករបស់អាម៉េរិកហើយត្រូវបានគេស្គាល់ឈ្មោះក្រោមម៉ាកសញ្ញា Levi's។

តាមរយៈជំនួបនាឱកាសនេះ តំណាងក្រុមហ៊ុន Levi Strauss & Co ក៏បានបង្ហាញការស្វាគមន៍ជូនដល់គណៈប្រតិភូកម្ពុជា ព្រមទាំងបានជម្រាបជូនអំពីសាវតាររបស់ក្រុមហ៊ុន និងតម្រូវការនានាដែលជាមូលដ្ឋានដល់ការសម្រេចចិត្តដើម្បីពង្រីកអាជីវកម្មរបស់ខ្លួនដូចជាការប្រើប្រាស់ថាមពលស្អាតសំដៅធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

ស្របតាមការលើកឡើងខាងលើនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានលើកទឹកចិត្តឱ្យក្រុមហ៊ុនពិនិត្យលទ្ធភាពក្នុងការបណ្តាក់ទុនវិនិយោគពង្រីកវិសាលភាពផលិតកម្មរបស់ខ្លួននៅកម្ពុជា តាមរយៈកិច្ចសម្របសម្រួលលើការងារវិនិយោគពីសំណាក់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក៏ដូចជាភាគីពាក់ព័ន្ធដែលអាចធានាបាននូវបរិយាកាសវិនិយោគប្រកបដោយភាពអនុគ្រោះបំផុត។ជាមួយប្រធានបទនៃការវិនិយោគក្នុងវិស័យនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានជម្រាបជូនអំពីបច្ចុប្បន្នភាពការផលិត និងផ្គត់ផ្គង់ថាមពលនៅប្រទេសកម្ពុជាដែលក្នុងនោះ ៦២%នៃថាមពលសរុបដែលបានប្រើប្រាស់សម្រាប់ការផ្គត់ផ្គង់គឺជាប្រភេទថាមពលស្អាត និងកកើតឡើងវិញ។







## អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ក្នុងជំនួបសំណេះសំណាល និងពិភាក្សាការងារជាមួយ លោកជំទាវ Karen Bass អភិបាលក្រុងឡូសអែនជែលលេស នៃរដ្ឋកាលីហ្វ័រញ៉ា











ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញដឹកនាំគណៈប្រតិភូអមដំណើរទាំងផ្នែករដ្ឋ និងតំណាងសមាគមឧកញ៉ាកម្ពុជា ដឹកនាំដោយ អ្នកឧកញ៉ា ហ៊ុន ឡាក់ ចូលជួបសំណេះសំណាល និងពិភាក្សាការងារជាមួយ លោកជំទាវ Karen Bass អភិបាលក្រុងឡូសអែនជែលលេស នៃរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាម៉េរិកកាលពីព្រឹកថ្ងៃអង្គារ ទី២៤ ខែកញ្ញា ឆ្នាំ២០២៤។

ជាមួយនឹងការទទួលស្វាគមន៍ដ៏រាក់ទាក់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានលើកឡើងអំពីបច្ចុប្បន្នភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់កម្ពុជាដោយបានសង្កត់ធ្ងន់លើសន្តិភាព ស្ថិរភាពនយោបាយ កម្លាំងពលកម្មវ័យក្មេងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងត្រៀមរួចរាល់សម្រាប់បរិវត្តកម្មឌីជីថលជាមួយនឹងសមត្ថភាពភាសាបរទេសមានកម្រិតខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធអន្តរមធ្យោបាយដែលបាន និងកំពុងអភិវឌ្ឍឱ្យកាន់តែមានភាពសម្បូរបែប និងប្រទាក់ក្រឡាខណៈដែលបរិយាកាសវិនិយោគរបស់កម្ពុជាមានលក្ខណៈបើកចំហរនិងមានអំណោយផលខ្ពស់ជាងគេក្នុងតំបន់អាស៊ានសម្រាប់វិនិយោគិនបរទេសដែលនេះគឺជាការទទួលស្គាល់ពីសំណាក់ធនាគារពិភពលោកដែលជាស្ថាប័នហិរញ្ញវត្ថុលំដាប់អន្តរជាតិដ៏ធំមួយ។

ជាការឆ្លើយតប លោកជំទាវអភិបាលក្រុង បានកត់សម្គាល់ និងវាយតម្លៃខ្ពស់លើការខិតខំរបស់កម្ពុជាក្នុងការអភិវឌ្ឍខ្លួនឱ្យដើរទាន់បរិបទសង្គមជាសកលនិងបានបង្ហាញនូវចំណាប់អារម្មណ៍ក្នុងការអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជាសំដៅរឹតបន្តឹងចំណងមិត្តភាពរវាងប្រទេសទាំងពីរនិងដើម្បីស្វែងយល់បន្ថែមឱ្យកាន់តែស៊ីជម្រៅអំពីតថភាពសង្គម និងបរិយាកាសសេដ្ឋកិច្ចផងដែរ។

## សិក្ខាសាលាស្តីពី "បរិយាកាសវិនិយោគនៅកម្ពុជា" បង្ហាញជូនអំពីវឌ្ឍនភាពថ្មីៗដល់វិស័យឯកជន ដែលមានមូលដ្ឋានក្នុងក្រុងឡុងប៊ិច និងក្រុងឡូសអែនជែលលេស

កាលពីវេលាថ្ងៃត្រង់ ថ្ងៃអង្គារ ទី២៤ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញជាអធិបតី និងផ្តល់សុន្ទរកថាគន្លឹះក្នុងសិក្ខាសាលាស្តីពីការវិនិយោគនៅកម្ពុជា ដែលបានសហការរៀបចំដោយរដ្ឋបាលកំពង់ផែក្រុងឡុងប៊ិច (Port of Long Beach) ដើម្បីបង្ហាញជូនអំពីវឌ្ឍនភាពថ្មីៗដល់វិស័យឯកជនដែលមានមូលដ្ឋានក្នុងក្រុងឡុងប៊ិចនិងក្រុងឡូសអែនជែលលេសរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាម៉េរិក។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានរំលេចអំពីសក្តានុពលរបស់ព្រះរាជាណាចក្រកម្ពុជា រួមមាន ស្ថិរភាពនយោបាយ,ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចដែលមានលំនឹង,កម្លាំងពលកម្មវ័យក្មេងប្រកបដោយថាមវន្ត,រាជរដ្ឋាភិបាលដែលមានទំនោរគាំទ្រដល់ការរីកលូតលាស់នៃធុរកិច្ចឯកជន,របបវិនិយោគដែលមានភាពទាក់ទាញនិងអនុគ្រោះព្រមទាំងហេដ្ឋារចនាសម្ព័ន្ធអន្តរមធ្យោបាយដែលបាន និងកំពុងអភិវឌ្ឍឱ្យកាន់តែមានភាពតភ្ជាប់ និងប្រទាក់ក្រឡា។

អង្គសិក្ខាសាលាក៏បានរៀបចំឱ្យមានជាវេទិកាពិភាក្សាផ្លាស់ប្តូរយោបល់រវាងវិស័យឯកជនរួមមានប្រតិភូសមាគមឧកញ៉ាកម្ពុជាផងដែរដែលបានអមដំណើរឯកឧត្តមឧបនាយករដ្ឋមន្ត្រីពីកម្ពុជាជាមួយនឹងធុរជនមានមូលដ្ឋានក្នុងក្រុងឡុងប៊ិចនិងក្រុងឡូសអែនជែលលេសដែលបានចូលរួមនាឱកាសនោះដោយបានគូសបញ្ជាក់អំពីភាពងាយស្រួលក្នុងការប្រកបអាជីវកម្មនៅកម្ពុជា ពិពិធភាពនៃសកម្មភាពវិនិយោគដែលពោរពេញដោយឱកាស និងការគាំទ្រផ្នែកគោលនយោបាយប្រកបដោយបុរេសកម្មពីសំណាក់រាជរដ្ឋាភិបាល។

សូមជម្រាបជូនថា ក្នុងសិក្ខាសាលានេះដែរក៏មានការចុះអនុស្សារណៈនៃការយោគយល់គ្នារវាងក្រុមហ៊ុន Shun Fat Group តំណាងដោយលោកស្រី Ivy Tran នាយកគ្រប់គ្រងរបស់ក្រុមហ៊ុនជាមួយនឹងសហព័ន្ធស្រូវអង្ករកម្ពុជា តំណាងដោយ ឧកញ៉ា សុង សារ៉ន ប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអាជីវកម្ម និងលើកកម្ពស់បន្ថែមទៀតលើការនាំចេញស្រូវអង្ករពីកម្ពុជា ទៅកាន់សហរដ្ឋអាម៉េរិក ដែលនេះគឺជាអនុស្សារណៈទី៣ពាក់ព័ន្ធនឹងវិស័យស្រូវអង្ករដែលត្រូវបានចុះអំឡុងពេលបំពេញបេសកកម្មគោះទ្វារវិនិយោគនេះ។
















## ឯកឧត្តម ស៊ុន ចាន់ថុល ដឹកនាំប្រតិភូកម្ពុជា
## អញ្ជើញទស្សនកិច្ចទីស្នាក់ការកណ្តាលក្រុមហ៊ុន SpaceX របស់លោក Elon Musk

តបតាមការគោរពអញ្ជើញរបស់ក្រុមហ៊ុន SpaceX គណៈប្រតិភូកម្ពុជា ដឹកនាំដោយឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រីអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបំពេញទស្សនកិច្ចនៅទីស្នាក់ការកណ្តាលក្រុមហ៊ុន SpaceX របស់លោក Elon Musk កាលពីរសៀលថ្ងៃអង្គារ ទី២៤ ខែកញ្ញា ឆ្នាំ២០២៤ ដែលមានទីតាំងស្ថិតក្នុងតំបន់ Hawthorne ដើម្បីសិក្សាស្វែងយល់បន្ថែមអំពីទំនើបកម្មបច្ចេកវិទ្យាទំនើបថ្មីៗប្រព័ន្ធប្រតិបត្តិការផ្កាយរណបក៏ដូចជារបៀបរបបនៃការបង្កើនប្រសិទ្ធភាពការងារ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗជាច្រើនរបស់ក្រុមហ៊ុន ជាពិសេសប្រតិបត្តិការក្រុមផ្កាយរណប Starlink ជាដើម។

គួរជម្រាបដែរថា Starlink គឺជាក្រុមផ្កាយរណបអ៊ីនធឺណិត ដែលផ្តត់ផ្គង់សេវាអ៊ីនធឺណិតល្បឿនលឿនចល័តជាសកលគ្របដណ្តប់ជាង ១០០ប្រទេសនៅលើពិភពលោក។ ប្រតិបត្តិការនេះដំណើរការដោយ Starlink Services, LLC ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន SpaceX ។









# កិច្ចពិភាក្សាជាមួយថ្នាក់ដឹកនាំរតនាគារនៃរដ្ឋកាលីហ្វ័រញ៉ាសហរដ្ឋអាម៉េរិក ក្នុងគោលបំណងផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយអំពីបរិយាកាសវិនិយោគនៅកម្ពុជា











កាលពីរសៀលថ្ងៃអង្គារ ទី២៤ ខែកញ្ញា ឆ្នាំ២០២៤ ប្រតិភូសមាគមឧកញ៉ាកម្ពុជា បានអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈប្រតិភូកម្ពុជាចូលជួបសំណេះសំណាល និងពិភាក្សាការងារជាមួយអ្នកតំណាងលោកស្រីនាយកហិរញ្ញិក នៃរតនាគារនៃរដ្ឋកាលីហ្វ័រញ៉ាសហរដ្ឋអាម៉េរិក។

ក្នុងជំនួបនាឱកាសនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានជម្រាបជូនអង្គប្រជុំអំពីកាលានុវត្តភាពវិនិយោគនៅកម្ពុជាភាពរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធពាសពេញផ្ទៃប្រទេសសក្តានុពលនៃកម្លាំងពលកម្មដែលសុទ្ធសឹងជាយុវជន និងដែលមានចំណេះដឹងភាសាបរទេសអាចប្រើប្រាស់បានសម្រាប់ការទំនាក់ទំនងនិងការអនុវត្តកិច្ចការងារផ្សេងៗ។ តាមរយៈជំនួបនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មានសុទិដ្ឋិនិយមថានឹងទទួលបានការគាំទ្រពី រតនាគារនៃរដ្ឋកាលីហ្វ័រញ៉ា ក្នុងការចូលរួមជួយផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយអំពីបរិយាកាសវិនិយោគនៅកម្ពុជា ស្របតាមការតាំងចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាល ដែលមានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសេនាធិការនឹងសម្របសម្រួលរាល់កិច្ចការងារនានារបស់វិនិយោគិនដែលមានគម្រោងបណ្តាក់ទុន និងកំពុងបណ្តាក់ទុនវិនិយោគនៅកម្ពុជាផងដែរ។

## ប្រតិភូសមាគមឧកញ៉ាកម្ពុជាមានក្តីសោមនស្សរីករាយដែលបានជួបសំណេះសំណាលសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋខ្មែរ-អាម៉េរិកាំង ដែលកំពុងរស់នៅក្រុងឡុងប៊ិច នៃរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាម៉េរិក

នាថ្ងៃអង្គារទី២៤ខែកញ្ញា ឆ្នាំ២០២៤អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជារួមជាមួយប្រតិភូសមាគមឧកញ៉ាកម្ពុជា បានចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងពិធីជួបសំណេះសំណាលសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋខ្មែរ អាម៉េរិកាំង ដែលកំពុងរស់នៅក្រុងឡុងប៊ិច នៃរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាម៉េរិក នៅស្ថានកុងស៊ុលកិត្តិយសកម្ពុជា ប្រចាំក្រុងឡុងប៊ិច។

ក្នុងពេលវេលាប្រកបដោយសេចក្តីសោមនស្សនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានបង្ហាញនូវក្តីសប្បាយរីករាយចំពោះវត្តមានបងប្អូនពលរដ្ឋខ្មែរ-អាម៉េរិកាំងទាំងអស់ដែលបានទទួលស្វាគមន៍និងបានជម្រាបជូនអំពីភាពរីកចម្រើនថ្មីៗរបស់កម្ពុជាលើគ្រប់វិស័យពិសេសក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធទាំងផ្លូវថ្នល់ព្រលានយន្តហោះហើយពិសេសថ្មីៗនេះ កម្ពុជាបានបើកជាផ្លូវការ ការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ដែលនឹងជំរុញភាពប្រកួតប្រជែងក្នុងវិស័យដឹកជញ្ជូនកម្ពុជាបានមួយកម្រិតបន្ថែមទៀត។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានអំពាវនាវឱ្យបងប្អូនពលរដ្ឋខ្មែរ-អាម៉េរិកាំង មិនថានៅសហរដ្ឋអាម៉េរិក ឬនៅប្រទេសផ្សេងទៀតក្តី ចូលរួមបន្តផ្សព្វផ្សាយអំពីសក្តានុពលរបស់ប្រទេសកម្ពុជាទាំងវិស័យទេសចរណ៍ ការវិនិយោគ ព្រមទាំងចូលរួមថែរក្សាឱ្យបានសុខសន្តិភាព គាំទ្ររាជរដ្ឋាភិបាលកម្ពុជា បញ្ជ្រាបព័ត៌មានពិតត្រឹមត្រូវ អំពីការអភិវឌ្ឍជាក់ស្តែងនៃសង្គមជាតិជាមូលដ្ឋានជំរុញកិត្តិនាមកម្ពុជាលើឆាកអន្តរជាតិផងដែរ។











# ជំនួបនាពិភាក្សាការងារជាមួយលោក Daniel Chapman ស្ថាបនិក និងជានាយកប្រតិបត្តិក្រុមហ៊ុន Argentem Creek ដើម្បីជម្រាបអំពីព័ត៌មានសក្តានុពលសម្រាប់ការវិនិយោគឯកជននៅប្រទេសកម្ពុជា











កាលពីព្រឹកថ្ងៃពុធ ទី២៥ ខែកញ្ញា ឆ្នាំ២០២៤ ប្រតិភូសមាគមឧកញ៉ាកម្ពុជា បានបន្តអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឱកាសជួបពិភាក្សាការងារជាមួយ លោក Daniel Chapman ស្ថាបនិក និងជានាយកប្រតិបត្តិក្រុមហ៊ុន Argentem Creek ដើម្បីជម្រាបអំពីព័ត៌មានសក្តានុពលសម្រាប់ការវិនិយោគឯកជននៅប្រទេសកម្ពុជា។

ជំនួបនាឱកាសនេះផ្តល់លទ្ធភាពជូនលោក Daniel Chapman បានពិភាក្សាការងារជាមួយ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី អំពីបច្ចុប្បន្នភាពការវិនិយោគឯកជនក្នុងប្រទេសកម្ពុជា ព្រមទាំងស្វែងយល់អំពីសក្តានុពល កាលានុវត្តភាពវិនិយោគ ពិសេសផ្តោតលើវិស័យកសិ-ឧស្សាហកម្ម ថាមពល ធនាគារ-ហិរញ្ញវត្ថុ និងវិធីសាស្ត្រជាដំណោះស្រាយរំហូរហិរញ្ញវត្ថុ ជូនដល់ក្រុមហ៊ុននានាដែលមានតម្រូវការផងដែរ។

ជាការឆ្លើយតប ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានជម្រាបជូនអំពីភាពបើកចំហរនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជាលើគ្រប់វិស័យនិងវិស័យជាអាទិភាពដែលត្រូវបានលើកទឹកចិត្តពីរាជរដ្ឋាភិបាលកម្ពុជា។បន្ថែមពីនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានបង្ហាញជូនអំពីវឌ្ឍនភាពនៃវិស័យថាមពលនិងវិស័យធនាគារហិរញ្ញវត្ថុរបស់កម្ពុជានាពេលបច្ចុប្បន្នផងដែរ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានអញ្ជើញលោកនាយកប្រតិបត្តិក្រុមហ៊ុន Argentem Creek ក្នុងការពិនិត្យលទ្ធភាពស្វែងរកពេលវេលាសមស្របណាមួយដើម្បីធ្វើទស្សនកិច្ចធុរកិច្ចទៅប្រទេសកម្ពុជា។

## ប្រតិភូសមាគមឧកញ៉ាកម្ពុជាចាប់ផ្ដើមបេសកកម្មនៅប្រទេសកាណាដាតាមរយៈជំនួបពិភាក្សាតុមូលស្ដីពីបរិយាកាសវិនិយោគនៅកម្ពុជាជូនបណ្ដាធុរជនក្នុងទីក្រុងម៉ុងត្រេអាល់














អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ រួមជាមួយសមាជិកសមាគមឧកញ៉ាកម្ពុជា បានចូលរួមក្នុងជំនួបពិភាក្សាតុមូលស្ដីពីបរិយាកាសវិនិយោគនៅកម្ពុជា កាលពីល្ងាចថ្ងៃព្រហស្បតិ៍ ទី២៦ ខែកញ្ញា ឆ្នាំ២០២៤ ដែលត្រូវបានរៀបចំឡើងនៅទីក្រុងម៉ុងត្រេអាល់ ប្រទេសកាណាដា ខណៈដែលគណៈប្រតិភូកម្ពុជាដឹកនាំដោយ ឯកឧត្ដម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមានការចូលរួមពីសមាជិក សមាជិកានៃក្រុមប្រឹក្សាធុរកិច្ចកាណាដា-អាស៊ាន (Canada-ASEAN Business Council- CABC) ដឹកនាំដោយលោក Louis Vachon ជាសហប្រធានប្រចាំកាណាដានៃ CABC, តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់កម្ពុជា, ឯកឧត្ដម AlanBowmanអគ្គនាយកកិច្ចការសកលរបស់កាណាដាទទួលបន្ទុកអាស៊ីអាគ្នេយ៍ និងអូសេអានី តំណាងរដ្ឋាភិបាលកាណាដា, លោក Stephane Achard អនុប្រធានប្រតិបត្តិផ្នែកអន្តរជាតិ នៃធនាគារជាតិកាណាដា, និងវិស័យឯកជនកម្ពុជា-កាណាដាជាច្រើនរូបផងដែរ។

ក្នុងជំនួបនាឱកាសនេះ ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី បានចែករំលែកព័ត៌មានជាមូលដ្ឋានជូនដល់អង្គប្រជុំបានជ្រាបនិងចូលរួមផ្សព្វផ្សាយបន្តអំពីវឌ្ឍនភាពថ្មីៗរបស់កម្ពុជាលើគ្រប់វិស័យក្រោមការគិតគូរយ៉ាងម៉ត់ចត់ពីរាជរដ្ឋាភិបាលកម្ពុជា ពិសេសគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលបានបន្តយកចិត្តទុកដាក់យ៉ាងពេញទំហឹង លើការកសាងមូលធនមនុស្ស, ការលើកកម្ពស់ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទទាំងរឹងនិងទន់, ព្រមទាំងការពង្រឹងវិស័យឯកជន និងធុរកិច្ចក្នុងវិស័យមានសក្ដានុពលនានាវិស័យកសិកម្មកសិ-ឧស្សាហកម្មការជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម និងឧស្សាហូបនីយកម្មជាដើម។

ជាលទ្ធផលនៃអង្គប្រជុំ សមាជិក សមាជិករបស់ក្រុមប្រឹក្សាធុរកិច្ចកាណាដា-អាស៊ាន ក៏រំលេចលើកឡើងអំពីចំណាប់អារម្មណ៍ខ្ពស់នឹងពិនិត្យលទ្ធភាពវិនិយោគនៅកម្ពុជាលើវិស័យមានជាអាទិ៍ ថាមពល និងកសិកម្មជាដើម។

## សមាគមឧកញ៉ាកម្ពុជា ចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយស្ថាប័ន Excellence IndustrielleSaint-Laurent (FISL) របស់ខេត្តកេបិចក្នុងគោលដៅពង្រឹងការវិនិយោគទ្វេភាគីនិងសម្របសម្រួលការផ្លាស់ប្តូរសេដ្ឋកិច្ច

អ្នកឧកញ៉ា ហ៊ុន ឡាក់ ជាសមាជិកក្រុមប្រឹក្សាភិបាល និងជាអគ្គលេខាធិការនៃសមាគមបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជា ជាមួយស្ថាប័ន Excellence Industrielle Saint-Laurent (FISL) របស់ខេត្តកេបិច តំណាងដោយលោក Allan DeSousa ជាអភិបាល តំបន់ Saint Laurent នៃក្រុងម៉ុងត្រេអាល់ដើម្បីបង្កើតលក្ខខណ្ឌអំណោយផលដល់កិច្ចសហប្រតិបត្តិការនានាក្នុងគោលដៅពង្រឹងការវិនិយោគទ្វេភាគី សម្របសម្រួលការផ្លាស់ប្តូរសេដ្ឋកិច្ច និងជំរុញការអភិវឌ្ឍគម្រោងអាជីវកម្មរួមគ្នារវាងតំបន់ Saint-Laurent នៃក្រុងម៉ុងត្រេអាល់ ខេត្តកេបិច ប្រទេសកាណាដា និងប្រទេសកម្ពុជាជារួម។

ពិធីនេះបានធ្វើឡើងកាលពីព្រឹកថ្ងៃសុក្រ ទី២៧ ខែកញ្ញា ឆ្នាំ២០២៤ (ម៉ោងនៅក្នុងតំបន់) ក្រោមអធិបតីភាពឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រីអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងអំឡុងចូលរួមកិច្ចប្រជុំតុមូលជាមួយ តំណាងរដ្ឋបាលខេត្តកេបិច, លោក Allan DeSousa អភិបាលតំបន់ Saint Laurent នៃក្រុងម៉ុងត្រេអាល់, និងធុរជនជាច្រើនរូប ក្រោមកិច្ចសហការរៀបចំពីសភាពាណិជ្ជកម្មកម្ពុជាប្រចាំក្រុងម៉ុងត្រេអាល់ និងអង្គភាព Investissement Québec International របស់កាណាដា។

ក្នុងជំនួបនាឱកាសនេះបានផ្តល់លទ្ធភាពឱ្យវិនិយោគិនថ្មីៗជាច្រើន មកពីវិស័យជាអាទិភាពចំនួន៥ រួមមានកសិកម្មនិងកសិឧស្សាហកម្ម, ឱសថ, ថាមពលកកើតឡើងវិញ, ទេសចរណ៍, និងបច្ចេកវិទ្យា ព្រមទាំងថ្នាក់ដឹកនាំនៃខេត្តកេបិចបានជ្រាបកាន់តែច្បាស់បន្ថែមទៀតអំពីសក្តានុពលវិនិយោគនៅកម្ពុជាតាមរយៈការធ្វើបទបង្ហាញពីឯកឧត្តមឧបនាយករដ្ឋមន្ត្រីផ្ទាល់ ព្រមទាំងការលើកទឹកចិត្តនានារបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមបទបង្ហាញរបស់ថ្នាក់ដឹកនាំនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ពិសេសជាងនេះ អ្នកចូលរួមក៏បានស្តាប់អំពីបទពិសោធន៍ជោគជ័យនៃកិច្ចវិនិយោគនៅកម្ពុជាដែលចែករំលែកដោយក្រុមហ៊ុនកាណាដាដែលកំពុងបណ្តាក់ទុនវិនិយោគរាប់ពាន់លានដុល្លារអាម៉េរិកនៅកម្ពុជា។







# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ដឹកនាំគណៈប្រតិភូកម្ពុជា ចូលជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាអាត្លង់ទិក (The Atlantic Council of United States)





ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជាចូលជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាអាត្លង់ទិក (The Atlantic Council of United States) ដឹកនាំដោយលោក Frederick Kempe ប្រធាន និងជានាយកប្រតិបត្តិរបស់ក្រុមប្រឹក្សា ដែលជាអង្គការឯករាជ្យមួយនៅសហរដ្ឋអាមេរិកធ្វើការពាក់ព័ន្ធនឹងវិស័យការងារអន្តរជាតិនាព្រឹកថ្ងៃចន្ទ ទី៣០ ខែកញ្ញា ឆ្នាំ២០២៤ ។ (ម៉ោងនៅក្នុងតំបន់)។

ក្នុងកិច្ចប្រជុំពិភាក្សាការងារនាឱកាសនេះក៏មានការអញ្ជើញចូលរួមពីឯកឧត្តមឧត្តមសេនីយ៍JimJonesនាយកប្រតិបត្តិនៃក្រុមហ៊ុន Jones Group International, ឯកឧត្តម William Heidt អតីតឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជាចន្លោះពីឆ្នាំ២០១៥-២០១៨,ឯកឧត្តមPatrickMurphyអតីតឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជាក្នុងឆ្នាំ២០១៩-២០២៤ និងតួអង្គសំខាន់ៗជាច្រើនទៀតផងដែរ។

ក្នុងកិច្ចពិភាក្សានាឱកាសនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានគូសរំលេចអំពីទំនាក់ទំនងទ្វេភាគីរវាងកម្ពុជាសហរដ្ឋអាមេរិក និងកិច្ចខិតខំរបស់គ្រប់ភាគីពាក់ព័ន្ធ មានជាអាទិ៍ក្នុងវិស័យវិនិយោគ បានបន្តឥតដាច់ដើម្បីរក្សាបាននូវកំណើនការវិនិយោគដោយផ្ទាល់ពីសហរដ្ឋអាមេរិកមកកម្ពុជា។ ជាថ្មីម្តងទៀតក្នុងជំនួបនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានរំលេចជូនអង្គពិធីទាំងមូលអំពីកំណើននៃការវិនិយោគឯកជននៅកម្ពុជាក្នុងនីតិកាលទី៧នៃរដ្ឋសភាដែលកើនឡើងរហូតដល់៧៥% ដែលគិតជាគម្រោងមានចំនួន១៦៨គម្រោង។ កម្ពុជាបានបន្តខិតខំប្រឹងប្រែងក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាមិនត្រឹមតែសម្រាប់បម្រើប្រយោជន៍ពលរដ្ឋដោយផ្ទាល់ប៉ុណ្ណោះទេ ក៏ប៉ុន្តែសម្រាប់

សម្រួលការដឹកជញ្ជូនរបស់វិនិយោគិនផងដែរ។ គម្រោងនានាមានជាអាទិ៍ដូចជាគម្រោងពង្រីកកំពង់ផែអន្តរជាតិទឹកជ្រៅក្រុងព្រះសីហនុ និងគម្រោងព្រែកជីកជាដើម ដែលសុទ្ធសឹងតែនឹងចូលរួមបង្កើនតម្លៃប្រកួតប្រជែងផ្នែកភស្តុភារកម្មរបស់កម្ពុជា។ ដោយហេតុថាកម្ពុជាស្ថិតនៅចំកណ្តាលនៃតំបន់អាស៊ាន មានប្រជាពលរដ្ឋប្រមាណ១៧លាននាក់ ដោយក្នុងនោះប្រជាពលរដ្ឋវ័យក្មេងមានប្រមាណជាង ៦០% ច្រើនជាងប្រទេសផ្សេងៗទៀតក្នុងតំបន់។ ចំពោះទីផ្សារ កម្ពុជាភ្ជាប់ទៅកាន់អាស៊ាន មហាអនុតំបន់ទន្លេមេគង្គ និងទីផ្សារនៃប្រទេសជាសមាជិកកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ ដែលសរុបមានប្រជាជនប្រមាណ ២,៣ពាន់លាននាក់ជាគោលដៅ។

បន្ថែមលើការលើកឡើងដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី លោក Casey Barnet ប្រធានសភាពាណិជ្ជកម្មអាម៉េរិកនៅកម្ពុជា ហើយក៏ជាប្រធាននិងស្ថាបនិកសាលាពាណិជ្ជកម្ម CamEd Cambodia ក៏បានលើកឡើងអំពីភាពវិជ្ជមានក្នុងកិច្ចការងារវិនិយោគឯកជន ដោយហេតុថាកម្ពុជាបានអនុញ្ញាតជូនវិនិយោគិនបរទេសទាំងអស់អាចក្លាយជាម្ចាស់កម្មសិទ្ធទាំងស្រុង១០០% នៃអាជីវកម្មរបស់ខ្លួននៅកម្ពុជា លើកលែងកម្មសិទ្ធដីធ្លី ពិសេសការទទួលបានការលើកទឹកចិត្តទៅតាមគម្រោងវិនិយោគផ្សេងៗ គឺដូចៗគ្នាដល់គ្រប់វិនិយោគិនទាំងកម្ពុជានិងបរទេស។

ជាការឆ្លើយតបលោក Frederick Kempe បានថ្លែងការកោតសរសើរចំពោះកិច្ចខិតខំរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក្នុងដំណើរបេសកកម្មនាឱកាសនេះ។ តាមរយៈអង្គប្រជុំនេះ ភាគីទាំងអស់នឹងខិតខំបន្ថែមទៀតចូលរួមផ្សព្វផ្សាយអំពីសក្តានុពលជាវិជ្ជមានរបស់កម្ពុជា ដើម្បីពង្រឹងបន្ថែមកិច្ចការងារវិនិយោគផ្ទាល់លើវិស័យមានជាអាទិ៍បច្ចេកវិទ្យាទូរគមនាគមន៍ និងចំណីអាហារជាដើម។

សូមជម្រាបជូនថា ក្រុមប្រឹក្សាអាត្លង់ទិកត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦១ គឺជាអង្គការឯករាជ្យមួយនៅសហរដ្ឋអាម៉េរិកធ្វើការពាក់ព័ន្ធនឹងវិស័យការងារអន្តរជាតិជំរុញកិច្ចសហប្រតិបត្តិការឆ្លងកាត់អាត្លង់ទិកការពារសន្តិសុខអន្តរជាតិជាពិសេសជំរុញនិងរក្សាវិបុលភាពសេដ្ឋកិច្ចពិភពលោក។







**អ្នកឧកញ៉ា ហ៊ុន ឡាក់ ចូលរួមអមដំណើរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបចង្អៀតជាមួយ ឯកឧត្តម Ted Osius និងជំនួបពិសារអាហារធុរកិច្ចជាមួយសមាជិក សមាជិកានៃក្រុមប្រឹក្សាធុរកិច្ចអាម៉េរិក-អាស៊ាន (US-ABC)**

កាលពីរសៀលថ្ងៃចន្ទ ទី៣០ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញមានជំនួបចង្អៀតជាមួយឯកឧត្តម Ted Osius ប្រធាន និងជានាយកប្រតិបត្តិនៃក្រុមប្រឹក្សាធុរកិច្ចអាម៉េរិក-អាស៊ាន (US-ABC) ដើម្បីពិភាក្សាពិនិត្យអំពីលទ្ធភាពក្នុងការរួមគ្នាពង្រឹង និងពង្រីកការវិនិយោគឯកជនពីសហរដ្ឋអាម៉េរិកមកកម្ពុជាឱ្យបានកាន់តែច្រើនបន្ថែមទៀត។ក្នុងជំនួបពិភាក្សាការងារនាឱកាសនេះក៏មានវត្តមានអញ្ជើញចូលរួមពី ឯកឧត្តម កែវ ឈា ឯកអគ្គរាជកម្ពុជាប្រចាំសហរដ្ឋអាម៉េរិក និងតំណាងក្រុមហ៊ុន Delphos ដែលជាក្រុមហ៊ុនមានបទពិសោធន៍ជាង៣០ឆ្នាំ លើការផ្តល់សេវាកម្មប្រឹក្សាផ្នែកហិរញ្ញវត្ថុឈានមុខគេមួយផងដែរ។

នារសៀលថ្ងៃដដែលនេះដែរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញចូលរួមក្នុងជំនួបពិសារអាហារធុរកិច្ចជាមួយសមាជិក សមាជិកានៃក្រុមប្រឹក្សាធុរកិច្ចអាម៉េរិក-អាស៊ាន (US-ABC) ប្រមាណ៥០រូបដើម្បីចែករំលែកព័ត៌មានសក្តានុពលអំពីកិច្ចវិនិយោគនៅកម្ពុជានិងលើកទឹកចិត្តវិស័យឯកជនរបស់សហរដ្ឋអាម៉េរិកឱ្យបណ្តាក់ទុនបន្ថែមទៀតនៅកម្ពុជា។

អាស្រ័យដោយកត្តាមានសុខសន្តិភាពពេញលេញស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចច្បាប់វិនិយោគអំណោយផលដោយបើកទូលាយសម្រាប់គ្រប់វិនិយោគិនទាំងក្នុងនិងក្រៅប្រទេស, កិច្ចព្រមព្រៀងពាណិជ្ជកម្មនានាជាច្រើន, ហេដ្ឋារចនាសម្ព័ន្ធពេញផ្ទៃប្រទេស, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានត្រៀមខ្លួនរួចរាល់ ដើម្បីផ្តល់ការពិគ្រោះយោបល់ និងសម្របសម្រួលរាល់នីតិវិធីវិនិយោគនានាជូនដល់បណ្តាវិនិយោគិនទាំងអស់របស់អាម៉េរិកដែលសម្រេចចិត្តបណ្តាក់ទុននៅកម្ពុជា។








# លោកអ្នកឧកញ៉ា ហុង ស៊ួន ស៊ីគង់ទ្រីវ ដឹកនាំសមាជិកសមាគមឧកញ៉ាកម្ពុជា ប្រគេនទេយ្យទាន និងបច្ច័យសម្រាប់ព្រះសង្ឃគង់នៅវត្តមហាមន្ត្រី ក្នុងរាជធានីភ្នំពេញ




នារសៀលថ្ងៃសុក្រ ១០រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា ហុង ស៊ួន ស៊ីគង់ទ្រីវ អនុប្រធានសមាគមឧកញ៉ាកម្ពុជាបានអញ្ជើញចូលរួមក្នុងពិធីប្រគេននិងទទួលទេយ្យទានរួមមានអង្ករ បច្ច័យ ភេសជ្ជៈ ប្រគេនព្រះតេជគុណព្រះខេមាភិរ័ក ឈឿន តន់ ព្រះរាជាគណៈថ្នាក់កិត្តិយស ព្រះធម្មធរព្រះអនុគណខណ្ឌបឹងកេងកងនិងជាព្រះចៅអធិការវត្តមហាមន្ត្រីរួមទាំងមន្ត្រីសង្ឃវត្តក្នុងឱកាសបុណ្យកាន់បិណ្ឌភ្ជុំបិណ្ឌតាមលំអានប្រពៃណីដ៏ល្អផូរផង់របស់ប្រជាជាតិខ្មែរយើង។ពិធីនេះក៏មានការអញ្ជើញចូលរួមពីសំណាក់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជាជាច្រើនរូបទៀតផងដែរ។

ព្រះតេជគុណ ព្រះខេមាភិរ័ក ឈឿន តន់ ព្រះរាជាគណៈថ្នាក់កិត្តិយស ព្រះធម្មធរព្រះអនុគណខណ្ឌបឹងកេងកង និងជាព្រះចៅអធិការវត្តមហាមន្ត្រីបានមានសង្ឃដីការថាសទ្ធាដ៏ជ្រះថ្លារបស់ លោកអ្នកឧកញ៉ា អ្នក ឧកញ៉ា និងឧកញ៉ា ជាថ្នាក់ដឹកនាំនិងសមាជិកសមាគមឧកញ៉ាកម្ពុជា ពិតជាបានរួមចំណែកដ៏សំខាន់ក្នុងការសម្រាលការលំបាកខ្វះខាតរបស់ព្រះសង្ឃទាំង៥១០អង្គ គណៈកម្មការវត្តយាយជីតាជី២១នាក់ និងសិស្ស និស្សិត ដែលកំពុង ស្នាក់នៅចំនួន១៥១នាក់ខណៈដែលវត្តអារាមដ៏ចំណាស់នេះកំពុងខិតខំកសាងនិងរៀបចំហេដ្ឋារចនាសម្ព័ន្ធដើម្បីជាគុណប្រយោជន៍ទាំងវិស័យពុទ្ធចក្រ និងអាណាចក្រ។ សូមជម្រាបថា អង្ករ ទេយ្យទាន សរុបមានចំនួន ១០តោនបច្ច័យ ៣០លានរៀល និង៧,៥០០ដុល្លារអាម៉េរិក,ភេសជ្ជៈ POWARAM ចំនួន ១០០កេស និងទឹកបរិសុទ្ធចំនួន ២០០កេស ជាការឧបត្ថម្ភពីសប្បុរសជនដូចខាងក្រោម៖

១. សមាគមឧកញ៉ាកម្ពុជា អង្ករ ៥តោន និងទឹកបរិសុទ្ធ ១០០កេស
២. លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវអ្នកឧកញ៉ា គីម ហ៊ាង អង្ករ៥តោន និងបច្ច័យ៣០លានរៀល
៣. លោកអ្នកឧកញ៉ា លាង យុន អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ជីប ម៉ុង គ្រុប បច្ច័យ ២,០០០ដុល្លារ
៤. លោកអ្នកឧកញ៉ា ហុង ស៊ួន ស៊ីគង់ទ្រីវ អនុប្រធានសមាគមឧកញ៉ាកម្ពុជា បច្ច័យ១,០០០ដុល្លារ
៥. ជំទាវអ្នកឧកញ៉ា អ៊ាន អេឡែន អនុប្រធានសមាគមឧកញ៉ាកម្ពុជា បច្ច័យ ១,០០០ដុល្លារ
៦. អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជំទាវអ្នកឧកញ៉ា អ៊ឹង ស៊ីស្រ៊ន បច្ច័យ ៥០០ដុល្លារ និងទឹកបរិសុទ្ធ ១០០ កេស
៧. អ្នកឧកញ៉ា ជៀម ផេន សមាជិកក្រុមប្រឹក្សាភិបាលសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវអ្នកឧកញ៉ា ហៃ សុភារី ភេសជ្ជៈ POWARAM ១០០ កេស និងបច្ច័យ ១០០០ដុល្លារ
៨. អ្នកឧកញ៉ា ឡាវ កាង សមាជិកក្រុមប្រឹក្សាភិបាលសមាគមឧកញ៉ាកម្ពុជា បច្ច័យ ៥០០ដុល្លារ
៩. ជំទាវអ្នកឧកញ៉ា លឹម ស្រីពៅ សមាជិកសមាគមឧកញ៉ាកម្ពុជា បច្ច័យ ៥០០ដុល្លារ
១០. ជំទាវអ្នកឧកញ៉ា ទី គឹមស្រ៊ាន សមាជិកក្រុមប្រឹក្សាភិបាលសមាគមឧកញ៉ាកម្ពុជា និងអ្នកឧកញ៉ា ឌុក ទីប៉ាណា សមាជិកសមាគមឧកញ៉ាកម្ពុជា បច្ច័យ ៥០០ដុល្លារ
១១. អ្នកឧកញ៉ាបណ្ឌិត សំ សុខនឿន សមាជិកសកម្មសមាគមឧកញ៉ាកម្ពុជា បច្ច័យ ៥០០ដុល្លារ

គួររំលឹកថា កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជាចំនួន ១៤រូប បានចូលរួមពិធីបុណ្យកាន់បិណ្ឌ៤ នៅវត្តកែវមុនីវង្ស៊ី (ហៅវត្ត កន្ទួត) ភូមិកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ដោយបានចូលរួមបច្ច័យក្នុងការចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុងអារាមនេះដោយមានទឹកប្រាក់សរុបចំនួន ២៧លានរៀល និង ៤៩០០ដុល្លារអាម៉េរិក ដោយបច្ច័យទាំងនេះជាសទ្ធាពីសមាគមឧកញ៉ាកម្ពុជា លោកអ្នកឧកញ៉ាប្រធាន រួមជាមួយថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជាចំនួន១៤រូបទៀតផងដែរ។








CAMBODIA
CAMBODIA




CAMBODIA













# បេសកកម្ម

១ តំណាង និងការពារផលប្រយោជន៍ក៏ដូចជាកិត្តិយសរបស់សមាជិក

២ កសាងទំនាក់ទំនងប្រកបដោយមិត្តភាព សាមគ្គីភាព សហប្រតិបត្តិការ ក្នុងមហាគ្រួសារខ្មកញ្ញា

៣ ជួយគ្នាទៅវិញទៅមក ផ្លាស់ប្តូរព័ត៌មាន និងការពិគ្រោះយោបល់

៤ បង្កើនកិត្យានុភាព ឧត្តមភាព និងគុណធម៌របស់ខ្មកញ្ញាឱ្យកាន់តែរីកចម្រើន និងរុងរឿងនាពេលអនាគតដោយផ្សារភ្ជាប់ការចូលរួមក្នុងសកម្មភាពសង្គម និងមនុស្សធម៌នានា

៥ លើកកម្ពស់ការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា ក្នុងព្រះរាជាណាចក្រកម្ពុជា

៦ ជំរុញផ្សព្វផ្សាយសក្តានុពល និងការលានុវត្តភាពនៃការវិនិយោគ ក្នុងព្រះរាជាណាចក្រកម្ពុជា

៧ បង្កើតវេទិកា សិក្ខាសាលា និងកម្មវិធីផ្សេងៗពាក់ព័ន្ធនឹងធុរកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងវិស័យដទៃដើម្បីជាគុណប្រយោជន៍សម្រាប់សង្គមនិងសេដ្ឋកិច្ចជាតិ ។

# អត្ថប្រយោជន៍ក្នុងការក្លាយជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជា

| | |
|---|---|
| ១ | ក្លាយជាសមាជិកនៃមហាគ្រួសារឧកញ៉ាកម្ពុជាដែលប្រមូលផ្តុំដោយគោរមវន្តជាលោកអ្នកឧកញ៉ាអ្នកឧកញ៉ា និងឧកញ៉ាដែលសុទ្ធសឹងជាធុរជនកំពុងប្រកបអាជីវកម្មលើពហុវិស័យប្រកបដោយកិត្តិនាមល្អនៅក្នុងប្រទេសកម្ពុជាដែលជាប្រភពទាក់ទាញដៃគូវិនិយោគទាំងក្នុងនិងក្រៅប្រទេស |
| ២ | ទទួលបានឯកសណ្ឋានគោរមងារឧកញ៉ាចំនួន ១ឈុត និងអាំងស៊ីងឧកញ៉ាធ្វើអំពីមាស ១៨K ចំនួន ១ផងដែរ |
| ៣ | ទទួលបាននូវការចុះឈ្មោះចូលក្នុងគេហទំព័រនិងបញ្ជីផ្លូវការនៃគោរមងារឧកញ៉ារបស់ស.ឧ.ក.ដែលបញ្ជាក់ពីភាពច្បាស់លាស់របស់សមាជិកម្នាក់ៗក្នុងនាមជាឧកញ៉ា |
| ៤ | ទទួលបានឱកាសចូលរួមក្នុងកម្មវិធីនានាដូចជាវេទិកាធុរកិច្ចការផ្គូផ្គងដៃគូពាណិជ្ជកម្មនិងការកសាងបណ្តាញធុរកិច្ចជាមួយបណ្តាគោរមវន្តជាសមាជិករបស់ស.ឧ.ក.ព្រមទាំងជាមួយធុរជនក៏ដូចជាវិនិយោគិនជាតិនិងអន្តរជាតិ |
| ៥ | ទទួលបាននូវការធ្វើបច្ចុប្បន្នភាពជាប្រចាំអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងគោរមងារឧកញ៉ា |
| ៦ | ទទួលបានការលើកតម្កើងបន្ថែមទៀតនូវគុណតម្លៃព្រមទាំងឧត្តមភាព និងកិត្តិនាមនៃគោរមងារឧកញ៉ានៅក្នុងសង្គមតាមរយៈការផ្សព្វផ្សាយព័ត៌មានល្អៗចេញពី ស.ឧ.ក. |
| ៧ | ទទួលបានការគាំទ្រ និងការគាំពារ ទាំងផ្នែកច្បាប់ និងជំនួយស្មារតីក្នុងពេលមានបញ្ហា ឬវិវាទផ្សេងៗដោយឈរលើគោលការណ៍សាមគ្គីភាពដើម្បីដោះស្រាយបញ្ហាប្រឈម (ស្របច្បាប់) រួមគ្នា |
| ៨ | មានសិទ្ធិពេញលេញក្នុងការចូលរួមកិច្ចប្រជុំនិងពិធីជួបជុំនានារបស់ស.ឧ.ក.ដែលត្រូវបានរៀបចំឡើងដោយសមាគមឧកញ៉ាកម្ពុជា ជាពិសេសជំនួប និងការអមដំណើរប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាថ្នាក់ដឹកនាំនានានៅក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគព្រមទាំងសកម្មភាពពាណិជ្ជកម្ម និងធុរកិច្ចជាដើម |

# ទំនាក់ទំនងនិងទទួលបានព័ត៌មានអំពីយើងខ្ញុំតាមរយៈ

Website Facebook Telegram Youtube TikTok X(Twitter)

ទីស្នាក់ការ សណ្ឋាគារភ្នំពេញ លេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

(+៨៥៥) ២៣ ៨៦០ ៩៩៩ info@cambodianoknha.org www.cambodianoknha.org